ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MINISTRY OF LABOUR AND VOCATIONAL TRAINING

# ក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងការងារដោយបង្ខំ

## ភាគទី៤

ត្រីមាសទី២
ព.ស. ២៥៧០
គ.ស. ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

បោះពុម្ពលើកទី១

ព.ស. ២៥៧០ / គ.ស. ២០២៦

# កម្រងព័ត៌មានសេវាសាធារណៈ និងសេវាផ្សេងៗ

## ប្រព័ន្ធ Hotline

**1286 / 1297**

**24/7** ម៉ោង/សប្តាហ៍

សំណូមពរ

បណ្តឹងអនាមិក

តាមដានសេវាសាធារណៈ

ក្រុមតេឡេក្រាមសម្រាប់និយោជក

ក្រុមតេឡេក្រាមសម្រាប់កម្មករនិយោជិត

**App MLVT Services**
សម្រាប់ប្រព័ន្ធ **iOS**

**App MLVT Services**
សម្រាប់ប្រព័ន្ធ **Andriod**

អគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

# អារម្ភកថា

ចាប់តាំងពីការប្រកាសឱ្យប្រើ "ច្បាប់ស្តីពីការងារ" នៅឆ្នាំ១៩៩៧ មក ក្របខណ្ឌគតិយុត្តវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រឹងការអនុវត្ត និងរៀបចំជាបន្តបន្ទាប់ រួមមានការអនុម័តច្បាប់គ្រឹះចំនួន ៣ បន្ថែម និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ជាច្រើន ស្របតាមការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ចនៅកម្ពុជា សំដៅលើកកម្ពស់លក្ខខណ្ឌការងារ និងធានានូវសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីបង្កបរិយាកាសវិនិយោគកាន់តែមានភាពទាក់ទាញនិងប្រកួតប្រជែង។ ជាមួយគ្នានោះ លិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលបានរៀបចំក៏មិនទាន់ត្រូវបានប្រមូលផ្តុំចងក្រងឱ្យបានជាបណ្តុំឯកសារគតិយុត្តមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ភាគីនិយោជក និងកម្មករនិយោជិត អាច មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងសិក្សាស្វែងយល់បានទូលំទូលាយ។

ច្បាប់គ្រឹះទាំង ៤ រួមមាន ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងច្បាប់ស្តីពីរបបសន្តិសុខសង្គម ជាមូលដ្ឋានសម្រាប់ការដាក់ចេញនូវលិខិតបទដ្ឋានជាបន្តបន្ទាប់សំដៅលើកកម្ពស់លក្ខខណ្ឌការងារ ធានាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងអភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃសង្គម-សេដ្ឋកិច្ច។

ក្នុងគោលបំណងពង្រឹងនីត្យានុកូលភាព និងផ្តល់ភាពងាយស្រួលក្នុងការអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្រសួងបានរៀបចំ "**កម្រងលិខិតបទដ្ឋានគតិយុត្ត**" អនុលោមតាម ដោយរៀបចំចំណាត់ថ្នាក់លិខិតបទដ្ឋានគតិយុត្ត ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ និងមានមាតិកានុក្រមរួម ដោយត្រូវបានបែងចែកជា ៧ភាគ រួមមាន ភាគទី១ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអធិការកិច្ចការងារ, ភាគទី២ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការដោះស្រាយវិវាទការងារ, ភាគទី៣ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារ, ភាគទី៤ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនិងការងារដោយបង្ខំ, ភាគទី៥ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារនិងមុខរបរនិងហត្ថពលកម្មបរទេស, ភាគទី៦ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, និងភាគទី៧ កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបបសន្តិសុខសង្គម។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា "**កម្រងលិខិតបទដ្ឋានគតិយុត្ត**" នេះ នឹងក្លាយជាមគ្គុទេសក៍ដ៏សំខាន់ ដែលផ្តល់ឧត្តមប្រយោជន៍ជូនដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងនិយោជក កម្មករនិយោជិត អង្គការវិជ្ជាជីវៈ បញ្ញវន្ត និងសាធារណជនទូទៅ ជាមូលដ្ឋានសម្រាប់ពិគ្រោះ ស្វែងយល់ និងជាពុទ្ធិក្នុងការសិក្សាស្រាវជ្រាវ សំដៅរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ និងពង្រឹងប្រសិទ្ធភាពការងារឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

ថ្ងៃ ពុធ ៥រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

# មាតិកា

## ក្រមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
## ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងការងារដោយបង្ខំ

### ១- ព្រះរាជក្រឹត្យ


០១. លេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ.......... ២


### ២- អនុក្រឹត្យ


០១. លេខ ១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ( *និរាករណ៍ដោយអនុក្រឹត្យ លេខ ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)*.......... ៩


### ៣- ប្រកាស


០១. លេខ ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម.......... ១៦

០២. លេខ ១៤៤ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពីបដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើក្មេងធ្វើការពេលយប់.......... ១៩

០៣. លេខ ១៤៥ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី.......... ២១

០៤. លេខ ១០៦ សកបយ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់.......... ២៤

០៥. លេខ ៣០៥ កប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការងារនេសាទសមុទ្រ.......... ៣១

០៦. លេខ ៣០៦ កប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារនិងជីវភាពរស់នៅក្នុងចំការ.......... ៣៤

០៧. លេខ ៣០៧ កប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌអនាម័យ និងសន្តិសុខការងារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង.......... ៤២

០៨. លេខ ៣០៨ កប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសស្រែអំបិល.......... ៤៧

០៩. លេខ ៣០៩ កប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាព
រស់នៅក្នុងសហគ្រាសឡតដ្ឋ ....................................................................................៥០

១០. លេខ ០០២/០៨ កប/ប្រ.ក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ ស្តីពីការកំណត់ប្រភេទមុខរបរ
និងការងារស្រាល ដែលអនុញ្ញាតឱ្យកុមារអាចធ្វើការងារ ចាប់ពីអាយុ១២ ដល់១៥ឆ្នាំ ............... ៥៣

១១. លេខ ២៤០ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារ
ក្នុងមុខរបរផលិតកម្មដំឡូងមី ................................................................................ ៥៧

១២. លេខ ២៤១ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការងារកុមារ
ក្នុងមុខរបរនេសាទទឹកសាប ....................................................................................៦០

១៣. លេខ ២៤២ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការងារកុមារ
ក្នុងមុខរបរកសិកម្ម.............................................................................................. ៦៣

១៤. លេខ ២៤៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារ
ក្នុងមុខរបរផលិតកម្មថ្នាំជក់....................................................................................៦៦

១៥. លេខ ៤៦៧ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការជ្រើសរើស
កម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស គ្រឹះស្ថាន ......................................................៦៩

## ៤- សេចក្តីសម្រេច

០១. លេខ ១៥ ស.ស.រ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាព
គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ( *និរាករណ៍ដោយសេចក្តីសម្រេចលេខ ៧៧ ស.ស.រ
ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិ
ប្រឆាំងពលកម្មកុមារ)* ..........................................................................................៧៣

០២. លេខ ៧៧ ស.ស.រ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាព
គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ *( និរាករណ៍ដោយសេចក្តីសម្រេចលេខ ១៤ ស.ស.រ
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិ
ប្រឆាំងពលកម្មកុមារ)* ......................................................................................... ៧៦

០៣. លេខ ០៥៨/២២ ក.ប/ស.ស.រ.ខ.ល ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ស្តីពីការបង្កើត
ក្រុមការងារសម្រាប់សិក្សាស្រាវជ្រាវលទ្ធភាពផ្តល់ការអប់រំសិក្សាដល់កុមារដែលស្ថិតក្រោម
អាណាព្យាបាលរបស់កម្មករនិយោជិតចំណាកស្រុក និងពលករទៅធ្វើការនៅក្រៅប្រទេស..........៧៩

០៤. លេខ ១៤ សសរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាព
គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ.................................................................... ៨១

# ព្រះរាជក្រឹត្យ

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/១០៤៤

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨នៃអង្គការអន្តរជាតិខាងការងារស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

១/៦

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ព.** ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើសកម្មភាពជាបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

## ជំពូកទី២
## សមាសភាព គ.ជ.ព.

**មាត្រា២ .-**

មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | សមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

២/៦

- អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ សមាជិក
- អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក
- អគ្គលេខាធិការ **គ.ជ.ព.** សមាជិកអចិន្ត្រៃយ៍

សមាសភាពជាក់ស្តែងនៃ **គ.ជ.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ព.

**មាត្រា៣ .-**

**គ.ជ.ព.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជំរុញការអនុវត្តគោលនយោបាយ ផែនការសកម្មភាពជាតិ និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ជំរុញការអនុវត្តច្បាប់ស្តីពីការងារនិងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារអនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបានអនុសញ្ញាលេខ២៩ស្តីពីការងារដោយបង្ខំឬជាកាតព្វកិច្ចនិងអនុសញ្ញាពាក់ព័ន្ធផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន

- ចូលរួមអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ដោយសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- រៀបចំទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ធ្វើទំនាក់ទំនងជាមួយសហគមន៍ជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នាដើម្បីរកជំនួយឧបត្ថម្ភ ផ្លាស់ប្ដូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួម ក្នុងគោលដៅលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ស្រាវជ្រាវនិងជូនព័ត៌មានស្ដីពីសេចក្ដីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច
- ពិនិត្យនិងសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ព.**
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ព.

**មាត្រា៤ .-**

**គ.ជ.ព.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ប្រធាន **គ.ជ.ព.** អាចកោះអញ្ជើញប្រជុំវិសាមញ្ញបានតាមការចាំបាច់។

ក្នុងមួយឆ្នាំម្ដង **គ.ជ.ព.** ត្រូវធ្វើការបូកសរុបអំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារដើម្បីដាក់ជូនរាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ជ.ព.** មានសិទ្ធិទាក់ទងនិងអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធនានា តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ ដែលពុំមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ដើម្បីចូលរួមផ្ដល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍។

**មាត្រា៦ .-**

របៀបរបបនៃការប្រជុំ និងនីតិវិធីការងាររបស់ **គ.ជ.ព.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ព.**។

**មាត្រា៧ .-**

**គ.ជ.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីដំណើរការការងាររបស់ខ្លួន។

៤/៦

**មាត្រា៨ .-**

**គ.ជ.ព.** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្នុងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (នាយកដ្ឋានការងារកុមារ)។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ព.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩ .-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ព.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា១០ .-**

**គ.ជ.ព.** អាចបង្កើតគណៈកម្មការឬអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ដែលសមាសភាពដឹកនាំរបស់គណៈកម្មការឬអនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសពីសមាជិកនៃ **គ.ជ.ព.** និងមានមន្ត្រីជំនាញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចូលរួមជាសមាជិក ។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការឬអនុគណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ព.**។

**មាត្រា១១ .-**

**គ.ជ.ព.** ទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអ្នកជំនាញការអន្តរជាតិ មួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ **គ.ជ.ព.** និងអគ្គលេខាធិការដ្ឋាន។

**មាត្រា១២ .-**

**គ.ជ.ព.** ត្រូវបង្កើតគណៈកម្មការប្រឆាំងពលកម្មកុមារ រាជធានីខេត្ត។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត ត្រូវកំណត់ដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមការណែនាំរបស់ **គ.ជ.ព.**។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១៣ .-**

**គ.ជ.ព.** មានប្រភពធនធានពីថវិកាជាតិ ថវិកាដៃគូ និងប្រភពផ្សេងៗទៀតនៅក្នុងក្របខណ្ឌថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**គ.ជ.ព.** គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិរបស់ខ្លួន ស្របតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន និងធានាឲ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន។

ROYAL · LE MINISTRE DU PALAIS ROYAL

៥/៦

**ជំពូកទី៦**
**អវសានប្បញ្ញត្តិ**

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *១៧* ខែ *វិច្ឆិកា* ឆ្នាំ២០១៦

*៣៧៧.១២១១.១០៥៧*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខ:១០៣៩ ស.ណ
**សំណៅ[illegible]ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០១៦
**[illegible]ការរងរដ្ឋាភិបាល**

**សយ សុខា**

៦/៦

# អនុក្រឹត្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...១៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសហសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨នៃអង្គការអន្តរជាតិខាងការងារស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

១/៦

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដែលហៅថា អគ្គលេខាធិការដ្ឋាន **គ.ជ.ព.**។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ ..**

អគ្គលេខាធិការដ្ឋាន **គ.ជ.ព.** មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបច្ចេកទេសដែលធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ **គ.ជ.ព.**
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពី **គ.ជ.ព.** ដល់គ្រប់ក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ **គ.ជ.ព.**
- ពិនិត្យ តាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយ ផែនការសកម្មភាពជាតិ និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយ ផែនការសកម្មភាពជាតិនិងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- រៀបចំរបាយការណ៍ជូន **គ.ជ.ព.**
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ព.** ប្រគល់ជូន។

២/៦

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ព.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែកគោលនយោបាយនិងសហប្រតិបត្តិការ
- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ផ្នែកពិនិត្យ តាមដាន និងវាយតម្លៃ

អគ្គលេខាធិការដ្ឋាន **គ.ជ.ព.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបនិងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **គ.ជ.ព.** ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ផ្នែកគោលនយោបាយនិងសហប្រតិបត្តិការមានតួនាទីនិងភារកិច្ច៖

- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយ ផែនការសកម្មភាពជាតិ និងបទដ្ឋានទាំងឡាយ ដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- សហការជាមួយនឹងគណៈកម្មការឬអនុគណៈកម្មការជំនាញតាមវិស័យ ដើម្បីធានាការអនុវត្តតួនាទី និងភារកិច្ចដែលមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ
- សហការជាមួយសហគមន៍ជាតិនិងអន្តរជាតិ ដើម្បីធានាប្រសិទ្ធភាពការងាររបស់ **គ.ជ.ព.**
- សម្របសម្រួលជាមួយនឹងគណៈកម្មការឬអនុគណៈកម្មការជំនាញតាមវិស័យ ដើម្បីអភិវឌ្ឍសមត្ថភាពដល់គ្រប់ភាគីពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដើម្បីចងក្រងជាឯកសារសម្រាប់ជាធនធានដល់អ្នកសិក្សាស្រាវជ្រាវ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពី **គ.ជ.ព.** ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ជ.ព.** ប្រគល់ជូន។

**មាត្រា៥ .-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក និងឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ព.**
- រៀបចំនិងចាត់ចែងកិច្ចប្រជុំនានារបស់ **គ.ជ.ព.**
- រៀបចំរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ព.**
- បំពេញការងាររដ្ឋបាលនិងធានានិរន្តរភាពការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ព.**
- រៀបចំផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ព.** សម្រាប់រយៈពេលខ្លី មធ្យម និងវែង។

៣/៦

- គ្រប់គ្រងចំណូលចំណាយនិងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ព.
- រៀបចំគ្រប់គ្រងបញ្ជីសារពើភណ្ឌចលនទ្រព្យនិងអចលនទ្រព្យរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ព.
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍ និងលើកអនុសាសន៍ជូន គ.ជ.ព. ពិនិត្យនិងសម្រេច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ព. ប្រគល់ជូន។

**មាត្រា៦ .-**

ផ្នែកពិនិត្យ តាមដាន និងវាយតម្លៃមានតួនាទី និងភារកិច្ចដូចតទៅ៖

- ពិនិត្យ តាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយ ផែនការសកម្មភាពជាតិ និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ស្រាវជ្រាវនិងកំណត់សូចនាករចំណុចដៅសម្រាប់ការពិនិត្យ តាមដាន និងវាយតម្លៃ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដើម្បីកែលម្អយន្តការពិនិត្យ តាមដាន និងវាយតម្លៃ
- ប្រមូលទិន្នន័យនិងវិភាគលើលទ្ធផលនៃការអនុវត្តគ្រប់កម្មវិធីពាក់ព័ន្ធនឹងការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដើម្បីដាក់ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ព. ពិនិត្យ
- បូកសរុបការងារពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដាក់ជូន គ.ជ.ព. ដើម្បីពិនិត្យនិងសម្រេច
- ផ្សព្វផ្សាយលទ្ធផលនៃការពិនិត្យ តាមដាន និងការវាយតម្លៃដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ព. ប្រគល់ជូន។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន គ.ជ.ព. មានមន្ត្រីបម្រើការជាមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន គ.ជ.ព. អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

បែបបទនិងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ព.។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......១៦......អនក្រ.បក ចុះថ្ងៃទី...៩...ខែ...កុម្ភៈ...ឆ្នាំ២០១៨**

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

### អង្គការលេខនៃអគ្គលេខាធិការដ្ឋាន គ.ជ.ព.




**សម្គាល់**

- ទំនាក់ទំនងប្រយោល
- ទំនាក់ទំនងផ្ទាល់
- គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ (គ.ជ.ព.)

១/១

# ប្រកាស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ១២៤ ស.ក.ប.យ

ភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

បានឃើញស្មារតីនៃអង្គប្រជុំគណៈកម្មការប្រឹក្សាការងារ

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់រិះរកមធ្យោបាយចាំបាច់ ដើម្បីជៀសវាងកុំឱ្យការលើកដាក់ទម្ងន់មានគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ពិសេសកុំឱ្យមានការប៉ះពាល់ដល់ឆ្អឹងខ្នង ។

ក្នុងករណីដែលការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់មិនអាចជៀសវាងបានទេ ត្រូវធ្វើយ៉ាងណាកុំឱ្យការងារទាំងនោះបង្កគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ។

1

ការលើកដាក់ទម្ងន់ សំរាប់កម្មករនិយោជិកម្នាក់ឬច្រើននាក់ ជាអាទិ៍ :

- ការលើក
- ការដឹកនាំ
- ការដាក់ចុះ
- ការរុញ
- ការអូសទាញ
- ការរំកិល វត្ថុដែលមានទម្ងន់ដោយបញ្ចេញកម្លាំងពលកម្មផ្ទាល់ ។

ប្រការ២.- ដើម្បីជាវិធានការល្អក្នុងការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់នេះ និយោជកត្រូវ ៖

- រៀបចំកញ្ចប់ទម្ងន់និមួយៗកុំឱ្យទើសខែងនិងមិនលើសពី៥០គីឡូក្រាម
- រៀបចំផ្លូវឆ្លងកាត់ឱ្យបានជិតបំផុតនិងមិនយាំប់ធ្វើដំណើរ
- រៀបចំកម្មករនិយោជិតដែលចូលរួមធ្វើការលើកដាក់ទម្ងន់ដោយមិនបង្ខិតបង្ខំ
- រិះរកមធ្យោបាយបច្ចេកទេសជំនួយក្នុងការលើកដាក់ទម្ងន់
- ផ្តល់ដល់កម្មករនិយោជិតនូវការអប់រំពីបច្ចេកទេសលើកដាក់ទម្ងន់ ។

ប្រការ៣.- ស្ត្រីមានផ្ទៃពោះ ឬស្ត្រីទើបចូលធ្វើការឡើងវិញបន្ទាប់ពីសំរាលកូន ឬរលូតកូន ឬរំលូតកូន ក្នុងរយៈពេល២ខែដំបូង មិនអនុញ្ញាតឱ្យលើកទម្ងន់លើសពី៥គីឡូក្រាម ។

ប្រការ៤.- កម្មករនិយោជិតម្នាក់ មិនអនុញ្ញាតឱ្យ លើក ដាក់ អូស ទាញ រុញ ឬរំកិលទម្ងន់ ដោយកម្លាំងពលកម្មផ្ទាល់ ដែលមានចំនួនលើសពីទម្ងន់ដែលមានបង្ហាញក្នុងតារាងខាងក្រោមនេះ ៖

| សណ្ឋានទៃទម្ងន់ | បុរស | | ស្ត្រី | |
|---|---|---|---|---|
| | ចាប់ពី ១៥ឆ្នាំ | ចាប់ពី ១៨ឆ្នាំ | ចាប់ពី ១៥ឆ្នាំ | ចាប់ពី ១៨ឆ្នាំ |
| លើកដាក់ទម្ងន់ផ្ទាល់ | ១២គ.ក្រ | ៥០គ.ក្រ | ៦គ.ក្រ | ២៥គ.ក្រ |
| រទេះរុញកង់១ ផ្លូវក្នុងការដ្ឋាន | ៣២គ.ក្រ | ៨០គ.ក្រ | ហាម | ៤០គ.ក្រ |
| រទេះរុញកង់៣ឬ៤ ផ្លូវក្នុងការដ្ឋាន | ៤៨គ.ក្រ | ១២០គ.ក្រ | ២៤គ.ក្រ | ៦០គ.ក្រ |

2

ប្រការ៥.- បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចបញ្ជាក់ពីសេចក្តីច្បាស់លាស់នៃការរៀបចំការងារលើកដាក់ទម្ងន់ ។ ក៏ប៉ុន្តែសេចក្តីបញ្ជាក់នៃបទបញ្ជាផ្ទៃក្នុងនេះ មិនអាចផ្ទុយពីប្រការទាំងឡាយនៃប្រកាសនេះឡើយ ។

ប្រការ៦.- ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុង ជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៧.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ឞ

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីជូនជ្រាប
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សព្វផ្សាយនិងអនុវត្ត
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយនិងអនុវត្ត
- សមាគមនិយោជក ដើម្បីអនុវត្ត
- សហភាពសហជីព ដើម្បីជ្រាប
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ ដើម្បីជួយផ្សព្វផ្សាយ
- កាលប្បវត្តិ និងឯកសារ

3

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ១៤៤ សកបយ.

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
# ស្តីពី
# បដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើ
# ក្មេងធ្វើការពេលយប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំ រេ ច

**ប្រការ១.-** ក្មេងដែលមានអាយុពី១៦ឆ្នាំទៅក្រោម១៨ឆ្នាំ អាចប្រើអោយធ្វើការនៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រធ្វើកែវ រោងចក្រធ្វើក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរឥតឈប់ទាំងយប់ទាំងថ្ងៃ។ ការប្រើក្មេងអោយធ្វើការពេលយប់នៅក្នុងរោងចក្រទាំងនេះមានគោលបំណងតែមួយគឺ ដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្មេងតែប៉ុណ្ណោះ ។

**ប្រការ២.-** ក្នុងគ្រប់ករណីទាំងអស់ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេង មិនអាចលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ហើយ

ការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោចណាស់ ១៣ ម៉ោងជាប់គ្នា ។

**ប្រការ៣.**- និយោជកដែលចង់ប្រើក្មេងពេលយប់ ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេចតាមករណីក្មេងនិមួយៗ ដោយផ្អែកតាមមូលហេតុ នៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេង ដែលចេញដោយគ្រូពេទ្យការងារផង ។

**ប្រការ៤.**- នៅក្នុងគ្រឹះស្ថាន សហគ្រាសទាំងអស់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ និយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អោយធ្វើការនៅពេលយប់បាន ដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្រ បរិក្ខា ឬសម្ភារៈដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើ ត្រូវជូនដំណឹងអោយអធិការការងារបានដឹងជាមុនអំពីមូលហេតុ នៃការធ្វើបដិប្បញ្ញត្តិនេះ ។

**ប្រការ៥.**- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៨ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  " ដើម្បីជូនជ្រាប "

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

  " ដើម្បីជ្រាប "

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សភ
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៤៥ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

ប្រកាស
ស្តីពី
ការហាមឃាត់ការប្រើប្រាស់កុមារធ្វើជាឧបករណ៍ ដល់កុមារក្រោមអាយុ ១៨ ឆ្នាំ ដល់ក្មេងសំរាប់ធ្វើការក្រោមដី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ក្មេងអាយុពី១៦ ឆ្នាំ ទៅក្រោម ១៨ ឆ្នាំ អាចប្រើអោយធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្រោមដី បានតែក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និងជួយអោយក្មេងមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួន ប៉ុណ្ណោះ ។ ការប្រើក្មេងក្នុងមុខរបរប្រភេទនេះ ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរឹងដូចមានចែងក្នុងប្រការខាងក្រោម ។

**ប្រការ២.-** មុននឹងចូលធ្វើការ ក្មេងត្រូវទទួលការពិនិត្យកាយសម្បទាយ៉ាងម៉ត់ចត់ពីគ្រូពេទ្យការងារ រួមបញ្ចូលទាំងការថតសួតដោយវិទ្យុផង ។ ចំណាយលើការពិនិត្យកាយសម្បទាគឺជាបន្ទុករបស់និយោជក ។ វិញ្ញាបនប័ត្រកាយសម្បទា ដែលចេញដោយគ្រូពេទ្យការងារ ត្រូវរក្សាទុកដោយនិយោជក និងត្រូវបង្ហាញជូនអធិការការងារ ឬអធិការពេទ្យការងារតាមសំណើ ។ ការពិនិត្យកាយសម្បទានេះ ត្រូវធ្វើឡើងវិញរៀងរាល់រយៈពេល ៦ ខែ ។

**ប្រការ៣.-** និយោជកត្រូវមានសៀវភៅបញ្ជីសំរាប់ក្មេងដោយឡែកដែលក្នុងនោះត្រូវបញ្ជាក់ច្បាស់អំពី :-

-អាយុរបស់ក្មេង

-កាលបរិច្ឆេទ នៃការចុះក្រោមដីលើកទីមួយ

-ថិរវេលាសំរាកប្រចាំសប្តាហ៍

-ថិរវេលាសំរាកប្រចាំឆ្នាំ ។

**ប្រការ៤.-** មុននឹងចុះទៅធ្វើការក្រោមដី ក្មេងត្រូវទទួលការបណ្តុះបណ្តាលពិសេសដោយគ្រូស្ទាត់ជំនាញអំពី :-

-គ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាព និងសន្តិសុខការងារនៅក្រោមដី

-ការសង្គ្រោះបន្ទាន់

-វិធានការការពារគ្រោះថ្នាក់ ការប្រើប្រាស់បរិក្ខាសុវត្ថិភាព និងសេចក្តីណែនាំអំពីសន្តិសុខការងារ ។

**ប្រការ៥.-** ក្មេងដែលធ្វើការក្រោមដី ត្រូវតែស្ថិតក្រោមការដឹកនាំរបស់គ្រូបង្ហាត់ដែលមានការទទួលខុសត្រូវខ្ពស់ ។ ក្នុងករណីនេះក្មេងអាចជួយការងារក្នុងក្រុម ដើម្បីអោយមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួន ប៉ុន្តែពេលវេលាហ្វឹកហ្វឺនពិតប្រាកដយ៉ាងហោចណាស់ក៏ត្រូវស្មើនឹងពាក់កណ្តាលនៃពេលវេលាធ្វើការទាំងអស់របស់ក្មេងនៅក្រោមដីដែរ ។

**ប្រការ៦.-** ក្មេងដែលធ្វើការក្រោមដីមិនត្រូវទុកអោយធ្វើការដោយគ្មានការឃ្លាំមើលឡើយ ។ ហាមឃាត់មិនអោយប្រើក្មេងកាន់ឧបករណ៍គ្រឿងយន្តណា ឬប្រើប្រាស់នូវរបៀបធ្វើអាជីវកម្មណាដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ក្មេង ។

**ប្រការ៧.-** ក្មេងមិនអាចធ្វើការនៅក្រោមដីលើសពី ៤០ ម៉ោង ក្នុងមួយសប្តាហ៍ ឬ ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។

២

**ប្រការ៨.** កុមារដែលធ្វើការក្រោមដី ត្រូវបានទទួលសំរាកប្រចាំសប្តាហ៍ដែលមានរយៈពេលយ៉ាងហោចណាស់ ៤៨ ម៉ោង ជាប់ គិតរួមបញ្ចូលទាំងថ្ងៃអាទិត្យ និងមានសិទ្ធិយប់សំរាកប្រចាំឆ្នាំចំនួន ២៤ ថ្ងៃ បើបានធ្វើការជាប់ក្នុងមួយឆ្នាំ ទោះបីជាការធ្វើការនៅក្រោមដីមានលក្ខណៈមិនពេញពេលក៏ដោយ ។

**ប្រការ៩.** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៧ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១០.** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១០៦ សកបយ

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ០៧ ឆ្នាំ ២០០៤

## ប្រកាស
## ស្តីពី
## ការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម /០៣៩៧ /០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

## សំរេច

ប្រការ ១.- ហាមនិយោជកនៃសហគ្រាសគ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារមិនអោយប្រើប្រាស់កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ នៅក្នុងប្រភេទការងារ ដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ ។

១

ប្រសិនបើកុមារធ្វើការងារពុំមានឯកសារផ្លូវការណាមួយបញ្ជាក់ពីអាយុអោយបានត្រឹមត្រូវឬក៏អធិការការងារសង្ស័យថា ឯកសារមានការក្លែងបន្លំអាយុនោះ ត្រូវស្រាវជ្រាវករណីនេះនៅមូលដ្ឋានពាក់ព័ន្ធរបស់សាម៉ីខ្លួននៃកុមារនោះ ។

ពាក្យបច្ចេកទេសទាំងឡាយមានពន្យល់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២.- ការងារប្រកបដោយគ្រោះថ្នាក់គឺការងារដែលបណ្តាលអោយប៉ះពាល់សុខភាព សន្តិសុខ ឬសីលធម៌របស់កុមារ ជាអាទិ៍ :

១-ការរំលាយ ផ្សំ ដំ (ស្មិត) មូរ ដំពង្រាប ឬ ផ្សារលោហធាតុ

២-ការនេសាទ (ក្នុងទឹក និង លើផ្ទៃទឹកជ្រៅ)

៣-ការមុជទឹកដើម្បី លាងជូត រកខ្សែងខ្មៅ គុជ កើបខ្សាច់ និង គ្រួសអាចម៍ផ្កាយ

៤-ការកាប់ព្រៃឈើ

៥-ការដុតធ្យូង

៦-ការធ្វើការនៅកន្លែងម៉ាស៊ីនចំហាយ ម៉ាស៊ីនបូមខ្យល់ ម៉ាស៊ីនបញ្ចូលឧស្ម័នក្នុងបំពង់ ឬ ម៉ាស៊ីនផលិតឧស្ម័ន (អាសេទីឡែន) ការដឹកជញ្ជូន និង ការធ្វើការនៅក្នុងកន្លែងយកថ្ម ដូចជា ការខួង អុជ ធ្វើអោយផ្ទុះ បំបែកថ្ម ឬ កំទេចថ្ម

៧-ការបញ្ជាម៉ាស៊ីនកែច្នៃឈើ

៨-ការបញ្ជាម៉ាស៊ីនស្ទូច ម៉ាស៊ីនលើក កន្ត្រាក់ ម៉ាស៊ីនមានខ្សែសំរាប់លើកចុះឡើង ឬ ម៉ាស៊ីនសំរាប់លើកផ្សេងទៀត

៩-ការលើកដាក់ លីសែង យួរកាន់ និង ចលនារបស់ធ្ងន់ៗ (ដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ១២៤ សកបយ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកំម្លាំងពលកម្ម)

១០-ការពន្លត់អគ្គីភ័យ

១១-ការបើកបរ ឬ ជំនួយការបើកបរ(រួមមាន ការបញ្ឆេះម៉ាស៊ីន ការបញ្ជា ការតំរែតំរង់ ការថែទាំ ឬ សកម្មភាពផ្សេងទៀត ដែលទាក់ទងនឹងការប៉ះទង្គិចរាងកាយដែលបណ្តាលមកពីការបើកបរ) គ្រឿងចក្រ ដូចជា ម៉ាស៊ីនឈូសដី ឬ រុញដី រថយន្តសណ្តោងរ៉ឺម៉ក រ៉ូឡូកិនថ្ម ត្រាក់ទ័រសំរាប់លើកសម្ភារៈ ម៉ាស៊ីនជីកដី ម៉ាស៊ីនប្រមូលរបស់របរ ម៉ាស៊ីនផ្ទុកឥវ៉ាន់ រថយន្តដឹកទំនិញ រថយន្តក្រុង និង រថយន្តតាក់ស៊ី

១២-ការថែទាំ ជួសជុលម៉ាស៊ីនធុនធ្ងន់

១៣-ការធ្វើការនៅក្រោមដី ក្រោមទឹក គុហា ផ្លូវក្រោមដី អណ្តូងរ៉ែ និង ការយករ៉ែ ឬ យកថ្មក្នុងដី

១៤-ការធ្វើការពាក់ព័ន្ធនឹងវត្ថុដែលមានជាតិផ្ទុះ ជាតិអាស៊ីត កាំជ្រួច ឬ វត្ថុដែលងាយឆេះ លើកលែងតែ ការងារផ្តល់សេវាកម្មនៅក្នុងស្ថានីយ៍ប្រេងឥន្ធនៈ

១៥-ការធ្វើការនៅការដ្ឋានសាងសង់ លើកលែងតែកន្លែងពិសេស ដែលអធិការការងារអាចអនុញ្ញាតអោយកុមារធ្វើបាន និង កន្លែងមានសុវត្ថិភាព

១៦-ការធ្វើការនៅកន្លែងរុះរើ និងរំលំរំលាយ

១៧-ការធ្វើការនៅលើជណ្តើរ ឬ រន្ទាដែលមានកំពស់លើសពី ២,៥០ ម៉ែត្រឡើងទៅ( ដូចជា ការលាបថ្នាំ ជូសជុល ឬ សំណង់ កាត់មែកឈើ បេះផ្លែឈើ )

១៨-ការធ្វើការដែលពាក់ព័ន្ធទៅនឹងមេរោគសាស្ត្រ ដូចជា ការងារនៅមន្ទីរពិសោធន៍ ទឹកល្អស់អុយ និង គំនរសំរាម

១៩-ការធ្វើការដែលប៉ះពាល់វត្ថុដែលមានជាតិគីមី រូបសាស្ត្រ អេឡិចត្រូម៉ាញេទិច ឬ អ៊ីយ៉ុង ដូចជា

- រូបធាតុដែលមិនឆេះ
- បង់ហ្សែន
- កាត់មីូម
- បារត
- សំណ ស័ង្កសី ឧស្សាហកម្មលោហៈ សំណពណិស និង ថ្នាំលាបមានជាតិសំណ
- សារធាតុវិទ្យុសកម្ម វត្ថុដែលបញ្ចេញពន្លឺ
- កាំរស្មីស្វាយអ៊ុលត្រា កាំរស្មីឡាស័រ និង វិទ្យុបញ្ជូនប្រេកង់

២០-ការធ្វើការដែលពាក់ព័ន្ធទៅនឹងផ្សែង ធូលី ឧស្ម័ន និង សារធាតុដ៏ទៃទៀត ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់សុខភាព

២១-ការបាញ់ថ្នាំសម្លាប់សត្វល្អិត និង ថ្នាំសម្លាប់ស្មៅរុក្ខជាតិផ្សេងៗ

២២-ការបញ្ជាកំលាំងម៉ាស៊ីនរវៃខារអំបោះ និង វៃអំបោះ

២៣-ការជ្រលក់ពណ៌ ការបង្ហើយវាយនភ័ណ្ឌ ការបោកគក់ ការអ៊ុត ដែលការងារទាំង ៤ យ៉ាងនេះមានប្រើជាតិគីមី

២៤-ការតម្លើងបរិធានអគ្គិសនី រួមទាំង ការងារអូស ដាក់ខ្សែភ្លើង និង តខ្សែកាប

២៥-ការធ្វើការនៅក្បែរឡដុតកំដៅ រ៉ែ ក្លូម ថ្លាំង ជាផ្នែកមួយនៃដំណើរការរោងចក្រផលិតកែវ កុលាលភាជន៍ និង ផលិតឥដ្ឋ

២៦-ការផលិតភេសជ្ជៈដែលមានជាតិស្រវឹង ដូចជា ចំហុយស្រា ស្រាបៀរ និង ស្រាទំពាំងបាយជូរ

២៧-ការធ្វើការមួយចំនួននៅកន្លែងកំសាន្ត ដូចជាការបំរើគ្រឿងស្រវឹង ការគក់ច្របាច់ធ្វើសសៃ ការបំរើនៅក្នុងក្លឹបរាត្រី ការរាំកំដរភ្ញៀវក្រៅពីការសំដែងសិល្បៈ ។ ចំពោះការបណ្តុះបណ្តាលវិជ្ជាជីវៈ

៣

និង ការធ្វើកម្មសិក្សានិយោជកអាចអោយកុមារធ្វើការងារទាំងនេះបាន ។

២៨-ការធ្វើការដែលទាក់ទងទៅនឹងល្បែង ដូចជា ការចែកសន្លឹកបៀ ការស៊ីសងនៅតាមតុល្បែង និង ការទទួលលុយភ្នាល់

២៩-ការធ្វើការដែលពាក់ព័ន្ធទៅនឹងការផលិត ឬ ក៏ការដឹកជញ្ជូនថ្នាំញៀន ឬ ផលិតផលឱសថ

៣០-ការសំលាប់ស្បែក (កែច្នៃស្បែក)

៣១-ការធ្វើការជាឆ្មាំសង្គ្រោះនៅកន្លែងហែលទឹក និង ឆ្នេរងូតទឹកកំសាន្ត

៣២-ការធ្វើការនៅកន្លែងរោងជាងស្មិត

៣៣-ការធ្វើការនៅទីសត្តឃាត(កន្លែងសំលាប់សត្វ) និង ជាអ្នកផ្គត់សាច់

៣៤-ការចំហៀវខ្លាញ់ ឬ ប្រេង

៣៥-ការធ្វើការជាបុគ្គលិកសន្តិសុខ

៣៦-ការធ្វើការនៅក្នុងផ្នែកកីឡាដែលប្រកបដោយគ្រោះថ្នាក់ ដូចជា ការបង្ហាត់សេះ ការបង្ហាត់ បាញ់ស៊ីប ឬ នៅក្នុងសាលាបាញ់ស៊ីប

៣៧-ការបូជាសព

៣៨-ការធ្វើការទាំងឡាយដែលស្ថិតនៅក្នុងល័ក្ខខ័ណ្ឌក្តៅ ត្រជាក់ ញ័រ សំលេង និង ពន្លឺភ្លើងមិន ប្រក្រតី ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ ។

**ប្រការ ៣.-** យោងតាមសំណើរបស់និយោជក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា អាចពិនិត្យនិងសំរេចចេញសេចក្តីអនុញ្ញាតអោយកុមារដែលមានអាយុចាប់ពី ១៦ ឆ្នាំ ឡើង ធ្វើការងារប្រកបដោយគ្រោះថ្នាក់បានក្នុងល័ក្ខខ័ណ្ឌ :

- កុមារត្រូវបានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈត្រឹមត្រូវ
- មិនត្រូវអនុញ្ញាតអោយធ្វើការនៅចន្លោះពេលពីម៉ោង ២២:០០ ដល់ម៉ោង ៥:០០ ក្លី
- បានពិគ្រោះយោបល់ជាមួយគណៈកម្មការប្រឹក្សាការងារជាមុន ។

ចំពោះការងារនៅក្នុងអណ្តូងរ៉ែ ការយករ៉ែ ឬ យកថ្មក្នុងដី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា មិនអនុញ្ញាតអោយក្មេងអាយុក្រោម ១៨ ឆ្នាំ ធ្វើការងារនៅទីនោះទេ ។

នៅមុនពេលចាប់ផ្តើមធ្វើការងារ និង យ៉ាងហោចណាស់មួយឆ្នាំម្តងរហូតដល់កុមារមានអាយុ ១៨ ឆ្នាំ កុមារត្រូវតែអោយមានការពិនិត្យសុខភាពនៅក្នុងបរិបទនៃការងារដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ ដើម្បីបញ្ជាក់ថាមានសុខភាពល្អត្រឹមត្រូវ ។ ការពិនិត្យសុខភាពនេះត្រូវធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ ។

ប្រការ ៤.- ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា នឹងរៀបចំលិខិតបទដ្ឋានដោយឡែក ស្ដីពីការចាត់តាំងគណៈកម្មការកែសម្រួលបញ្ជីមុខរបរប្រកបដោយគ្រោះថ្នាក់ ។

ប្រការ ៥.- អ្នកប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬ ទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្ដីពីការងារ ។

ប្រការ ៦.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចំលងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និង អនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្ដាញវិទ្យុ និង ទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និង ឯកសារ

៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ
នៃប្រកាសលេខ ១០៦ សកបយ.
ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

## សេចក្ដីពន្យល់ពាក្យបច្ចេកទេស(ការងារគ្រោះថ្នាក់ដែលមានគ្រោះថ្នាក់)

| ពាក្យខ្មែរ | ភាសាអង់គ្លេស | សេចក្ដីពន្យល់ |
|---|---|---|
| ម៉ាស៊ីនបញ្ចូលឧស្ម័នក្នុងបំពង់ | Gas cylinders | ម៉ាស៊ីនបញ្ចូលសារធាតុមានក្លិន រាវ ពុល វិទ្យុសកម្ម ស្រាលជាងខ្យល់ ងុតឆេះ តាមបំពង់បង្ហូរ |
| អាសេទីឡែន | Acetylene | សារធាតុមានក្លិន រាវ ពុល វិទ្យុសកម្ម ស្រាលជាងខ្យល់ ងុតឆេះ (វត្ថុងាយឆេះ) |
| ម៉ាស៊ីនកែច្នៃឈើ | Powre-driven woodworking machine | ជាការកែច្នៃដោយកំលាំងម៉ាស៊ីនដែលប្រមូល និង កែច្នៃឈើមូល ឬ ឈើដែលបោះបង់ចោល ឬ សំណល់ ដើម្បីបំប្លែងទៅជាផលិតផលដែល អាចប្រើប្រាស់បាន |
| ម៉ាស៊ីនលើកកន្ទ្រាក់ | Lifting machine | ជាការលើកកន្ទ្រាក់ដោយកំលាំងម៉ាស៊ីន |
| ជាតិអាស៊ីត | Acid | សារធាតុដែលរលាយក្នុងទឹកបំបែកជាអ៊ីយ៉ុងផ្តល់ជាសូលុយស្យុងអាស៊ីតដែលមានក្លិនឈ្ងក់អាចធ្វើអោយស្ទះដល់ប្រព័ន្ធដកដង្ហើម និង មានរស់ជាតិពុលខ្លាំង |
| គីមី | Chemistry | វិទ្យាសាស្ត្រដែលសិក្សាអំពីទំរង់លក្ខណៈសមាសភាព និង បំលែងនៃអង្គធាតុ |
| រូបសាស្ត្រ | Physical | សំណុំវិទ្យាសាស្ត្រដែលសិក្សាអំពីលក្ខណៈរូបនៃរូបធាតុ (រឹង រាវ ឧស្ម័ន) |
| អេឡិចត្រូម៉ាញ៉េទិច | Electromagnetic | មេដែកអគ្គីសនី |
| អ៊ីយ៉ុង | Ion | ភាគល្អិត( អាតូម ឬ ក្រុមអាតូម)ដែលមានផ្ទុកបន្ទុកអគ្គីសនីបណ្តាលមកពីការបាត់បង់ ឬ ចំណេញអេឡិចត្រុង |

1

| | | |
|---|---|---|
| បង់ហ្សែន | Benzene | អ៊ីដ្រូកាបូប្រហើរ រាវ ទាញចេញពីធ្យូងថ្ម និង ប្រេងកាត ។ បង់សែនជាសារធាតុពុលខ្លាំងហើយអាចបណ្តាលអោយកើតជម្ងឺមហារីកឈាម |
| កាត់ម្ញ៉ូម | Cadmium | ជាលោហៈធន់ ទន់ ពណ៌ប្រាក់មាននិមិត្តសញ្ញា CD ។ កាត់ម្ញ៉ូមជាលោហៈពុលមានគ្រោះថ្នាក់ដល់សុខភាពមនុស្សដូចជា ចុះក្អួត រាគរូស ឬ រលាកសួត |
| បារត | Mercury | ជាសារធាតុពុលដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់សុខភាពមនុស្សយ៉ាងធ្ងន់ធ្ងរបណ្តាលមកពីការប៉ះពល់ដល់សរសៃប្រសាទ |
| ឧស្សាហកម្មលោហៈ | Metallurgy | ឧស្សាហកម្មដែលមានផ្នែកលោហៈចំលងកំដៅ និង អគ្គីសនីបានល្អ និង ជាទូទៅអាចហូតជាលួសបាន |
| សារធាតុវិទ្យុសកម្ម | Radioactive substances | ប្រភេទរូបធាតុនៃធាតុភូតដែលអង្គធាតុអាចបញ្ចេញដោយខ្លួនឯងនូវភាគល្អិតរបស់អាតូម ដូចជា ភាគល្អិតរបស់អាល់ផា និង ភាគល្អិតបែតា ឬ កាំរស្មីអេឡិចត្រូម៉ាញ៉េទិចដូចជា កាំរស្មីអ៊ិច និង កាំរស្មីកាម៉ាបណ្តាលមកពីការបំបែកណ្វៃយ៉ូ អតូម ឬ ប្រតិកម្មនុយក្លេអ៊ែរ |
| កាំរស្មីស្វាយអ៊ុលត្រា | Ultraviolet ray | ជាកម្មរស្មីដែលផ្នែកមនុស្សមើលពុំឃើញ |
| កាំរស្មីឡាស័រ | Laser | វត្ថុធាតុម្យ៉ាងដែលមានអំពូលឈ្មោះថា Monocromatic មានពណ៌តែ ១ ហើយបញ្ចេញកាំរស្មី |
| វិទ្យុបញ្ជូនហ្រ្វេកង់ | Radio-frequency emission | ឧបករណ៍សំរាប់បញ្ជូនតាមរលកធាតុអាកាស |
| វាយនភ័ណ្ឌ | Textile | ផលិតផលសំរេចនៃគីតម្បាញ |
| កុលាលភាជន៍ | Ceramic | វត្ថុដែលធ្វើអំពីដី ដូចជា ចាន ឆ្នាំង ក្អម |

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ[illegible] ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ៣០៥......កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

## ប្រកាស

## ស្តីពី

## ការងារនេសាទសមុទ្រ

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-** និយោជកនៃទូកនេសាទសមុទ្រទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួន ដើម្បីឱ្យការងារមានសុវត្ថិភាព និងមានជីវភាពរស់នៅដ៏សមរម្យមានអនាម័យត្រឹមត្រូវ។

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជកត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់ពីរសម្រាប់ក្នុង១រដូវ /ឆ្នាំ។ សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល ១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ មួយសម្រាប់ៗត្រូវមាន២ផ្នែកយ៉ាងតិច គឺសំពត់ឬខោ ហើយនិងអាវដែលមានទំហំស្របនឹង HS

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខ័ណ្ឌទួលគោក ផ្លូវប្រអប់សំបុត្រ P.O Box 1506 ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៨៣ ៥៣៨

ខ្លួនប្រាណ ព្រមទាំងសកម្មភាពការងាររបស់កម្មករ និយោជិត ។ និយោជកត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូ ជាដើម ។

បទបញ្ជាផ្ទៃក្នុង អាចកំណត់ពីលក្ខខណ្ឌដែលសម្លៀកបំពាក់នេះត្រូវបែងចែក ប្រើប្រាស់ និងថែទាំ ។

**ប្រការ ៣.- សម្ភារៈការពារបុគ្គល**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ ដូចជា អាវពោងមានចំណាំងផ្លាត និងកញ្ចែ អាវអៀមកៅស៊ូ អាវភ្លៀងនៅរដូវភ្លៀង ឬមួកហាមធំជាដើម ។ល។ និយោជក៏ត្រូវគិតគូរផងដែរ ឱ្យមានសម្ភារៈវិទ្យុទាក់ទងសម្រាប់ប្រើប្រាស់នៅពេលចាំបាច់ ។

**ប្រការ ៤.- ភេសជ្ជៈអនាម័យ**

និយោជកនៃទូកនេសាទសមុទ្រទាំងអស់ ត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិតរបស់ខ្លួន ស្របទៅតាមប្រកាសលេខ ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ។

**ប្រការ ៥.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម**

ការលើកដាក់ទម្ងន់ផ្សេងៗ ជាពិសេស សម្រាប់កុមារអាយុក្រោម១៨ឆ្នាំ ត្រូវអនុវត្តឱ្យបានស្របទៅតាមប្រកាសលេខ ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម ។

**ប្រការ ៦.- ការងារកុមារអាយុក្រោម១៨ឆ្នាំ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យចុះទូកទៅនេសាទដាច់ខាត ។ ចំពោះកុមារអាយុលើសពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ អាចអនុញ្ញាតឱ្យទៅចូលរួមធ្វើការនេសាទបាន តែក្នុងលក្ខខណ្ឌធ្វើតែការងារនៅលើទូកនេសាទប៉ុណ្ណោះមិន អនុញ្ញាតឱ្យចុះទឹក ឬមុជចុះក្នុងទឹកឡើយ ។

**ប្រការ៧.- សេវាសុខភាព**

និយោជកនៃទូកនេសាទសមុទ្រ ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករ និយោជិតរបស់ខ្លួន ស្របនឹងប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស ។៚

២

**ប្រការ ៨.-** ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ៩.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**វង សុត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ "**ដើម្បីជូនជ្រាប**"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "**ដើម្បីផ្សព្វផ្សាយ និងអនុវត្ត**"
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា "**ដើម្បីអនុវត្ត**"
- សហព័ន្ធសហជីព "**ដើម្បីជូនជ្រាប**"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "**ដើម្បីជួយផ្សព្វផ្សាយ**"
- កាលប្បវត្តិ និងឯកសារ

៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ៣០៦..........កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០០៧

**ប្រកាស**

**ស្តីពី**

**លក្ខខណ្ឌការងារនិងបរិយាកាសនៅក្នុងចំការ**

**រដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក/ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ប្រការ១.-** ដែនអនុវត្ត

និយោជកនៃចំការទាំងឡាយ ដែលមានលក្ខណៈជាឧស្សាហកម្ម ឬពាណិជ្ជកម្ម ហើយដែលដាក់ខ្លួនដាំដុះ និងផលិតដំណាំ ជាពិសេសដូចជាៈ តែ អំពៅ កៅស៊ូ ចេក ដូង សណ្តែកដី ថ្នាំជក់ ក្រូច ដូងប្រេង កាំងគីណា ឬម្នាស់ ម្រេច កប្បាស ក្រចៅ ឬដំណាំឧស្សាហកម្មដទៃទៀត ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតនិងគ្រួសារ លើបញ្ហាលក្ខខណ្ឌការងារ និងលក្ខខណ្ឌជីវភាព ។

**ប្រការ២.-** បទប្បញ្ញត្តិរួម

**សម្លៀកបំពាក់ការងារ**

និយោជកត្រូវផ្គត់ផ្គង់ដោយឥតគិតថ្លៃ ដល់កម្មករទាំងអស់នូវសម្លៀកបំពាក់ដែលរួមមាន ខោ អាវ និងស្បែកជើងការពារពលកម្ម ក្នុងមួយឆ្នាំពីរដង ។

1

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក. ប្រអប់សំបុត្រ P.O Box 1506 ទូរស័ព្ទ និង ទូរសារៈ (០២៣) ៣៥៣ ៥៥

**ឧបករណ៍និងការការពារបុគ្គល**

និយោជក ត្រូវផ្គត់ផ្គង់ដោយឥតគិតថ្លៃ ដល់បុគ្គលិកទាំងអស់នូវគ្រឿងបរិក្ខារ និងសំភារៈការពារបុគ្គល ដែលចាំបាច់ សំរាប់ធ្វើការងារ ។

**ការលីសែងនិងការលើកដាក់ដោយកម្លាំងពលកម្មនៅកន្លែងធ្វើការ**

ដំណើរការលីសែង និងលើកដាក់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ១២៤ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០១ ស្ដីពីការលើកដាក់ដោយកម្លាំងពលកម្ម ។

**សម្លេង**

សម្លេង និងសម្លេងខ្ទរ មិនត្រូវមានកំរិតលើសពីការកំណត់នៃប្រកាសលេខ ១៣៨ ស.ក.ប.យ ចុះថ្ងៃទី ២២/០៤/២០០៣ ស្ដីពីសម្លេងក្នុងទីកន្លែងធ្វើការ ។

**ការប្រឆាំងអគ្គីភ័យ**

និយោជកត្រូវចាត់គ្រប់វិធានការដែលចាំបាច់ដើម្បីការពារប្រឆាំងទល់នឹងអគ្គីភ័យ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាព ជាប្រយោជន៍ដល់ការសង្គ្រោះកម្មករនិយោជិត ។

**ប្រភេទនៃផលិតផលសំរាប់ពន្លត់ភ្លើងត្រូវមានលក្ខណៈសមស្របនៅនឹងហានិភ័យ**

និយោជកត្រូវរៀបចំបំរាម សំរាប់ករណីមានអគ្គីភ័យ ដាក់នៅតាមទីផ្សេងៗដូចជា ថ្នាលបណ្ដុះ និងផ្ទៃដីដាំដំណាំ រោងចក្រសំរាប់ធ្វើប្រព្រឹត្តកម្មនិងរូបបរិវត្តន៍ និងនៅទីតាំងរដ្ឋបាលជាដើម ។ បំរាមនេះត្រូវបិទផ្សាយ និងដាក់នៅទីដែលកម្មករនិយោជិត អាចមើលឃើញដោយងាយ ។ បំរាមនេះត្រូវធ្វើតាមរយៈការឱ្យសញ្ញាអាសន្ន និងលេខបញ្ជាក់ទីកន្លែង មធ្យោបាយ សំរាប់ការសង្គ្រោះបឋម សំភារៈពន្លត់ភ្លើង និងសង្គ្រោះ ។

**បំរាមការជក់បារី**

ដើម្បីបង្ការហានិភ័យនានា មានជាអាទិ៍ ហានិភ័យទាក់ទងដល់សុខភាព ហានិភ័យដោយអគ្គីភ័យ ទាក់ទងទៅនឹងប្រភេទវត្ថុធាតុដើម បរិស្ថាននៃចំការដំណាំ សារធាតុគីមីនិងធាតុផ្សំ គីមីដែលត្រូវប្រើ និយោជកត្រូវហាមឃាត់ មិនឱ្យជក់បារីនៅក្នុងបរិវេណនៃកន្លែងធ្វើការ ។

**ការបណ្ដុះបណ្ដាលនៅប៉ុស្តិ៍ការងារនិងសន្តិសុខ**

និយោជកត្រូវផ្ដល់ដល់កម្មករនិយោជិត ព្រមទាំងប្រតិភូបុគ្គលិក នូវការបណ្ដុះបណ្ដាលផ្នែកសន្តិសុខ សុខភាព និងអនាម័យការងារ ឱ្យបានសមស្រប ។

ការបណ្ដុះបណ្ដាលនេះ ត្រូវធ្វើការអនុវត្តជាក់ស្ដែង នៅនឹងប៉ុស្តិ៍ការងាររបស់កម្មករនិយោជិត ។

ការបណ្ដុះបណ្ដាលនេះ ត្រូវពន្យល់ដល់កម្មករនិយោជិត ជាអាទិ៍នូវ:

-កាយវិការនៃការអនុវត្តការងារល្អមានលក្ខណៈជាវិជ្ជាជីវៈ

-ហានិភ័យដែលត្រូវប្រឈម

-វិធានការនៃការបង្ការច្បាស់លាស់ អត្ថប្រយោជន៍របស់វា និងកិច្ចដំណើរការនៃប្រដាប់ការពារនីមួយៗ

-វិធានចរាចរសំរាប់ យានជំនិះ គ្រឿងចក្រ និងមនុស្ស នៅក្នុងបរិវេណដីនៃចំការដំណាំ

-វិធានប្រឆាំងអគ្គីភ័យ និងវិធាននៃការជម្លៀសចេញពីកន្លែងធ្វើការ ព្រមទាំងការកំណត់ន័យ នៃការផ្តល់សញ្ញាការសន្តិសុខ

-ការដឹកនាំជនរងគ្រោះ ពេលគ្រោះថ្នាក់ការងារ ឬពុល ដោយការងារ

-លក្ខខណ្ឌនៃការប្រើប្រាស់ទីតាំងផ្សេងៗ ដែលទុកបំរុងសំរាប់កម្មករនិយោជិត ។

**ការបណ្តុះបណ្តាលនេះត្រូវផ្តោតជាពិសេសលើ :**

-ហានិភ័យនៃជាតិគីមី និងការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់សារធាតុគីមី និងការរៀបចំនៅក្នុងសហគ្រាស

-ហានិភ័យនិងការប្រុងប្រយ័ត្ន ចំពោះការប្រើប្រាស់គ្រឿងម៉ាស៊ីន និងគ្រឿងបរិក្ខាការងារដទៃទៀត បច្ចេកទេសនៃការលើកដាក់ ការលីសែង និងការផ្ទេរទម្ងន់

-ហានិភ័យនិងការប្រុងប្រយ័ត្ន ចំពោះការធ្វើចរាចរយានជំនិះ និងគ្រឿងចក្រ ។

**ប្រការ៣._ ថ្នាល និងផ្ទៃដីដាំដុះ**

**ផ្លូវនិងច្រកចេញចូល**

និយោជកត្រូវថែរក្សាប្រព័ន្ធផ្លូវ និងច្រកចេញចូល ដែលតភ្ជាប់ពីរោងចក្រធ្វើប្រព្រឹត្តកម្មនិងរូបបរិវត្តន៍ ថ្នាលបណ្តុះ និងផ្ទៃដីដាំដុះ ព្រមទាំងផ្លូវក្នុងនៃកន្លែងទាំងនេះ ។

ផ្លូវសំរាប់ធ្វើចរាចរ ជាពិសេសតំបន់ចរាចរ តំបន់ផ្ទុកនិងផ្ទេរទំនិញ កន្លែងរង់ចាំ កន្លែងសំចត ត្រូវតែមានទំហំស្របតាម :

-ទទឹងនៃយាន និងគ្រឿងចក្រ

-ភាពទើសទែងនៃវត្ថុត្រូវដឹកជញ្ជូន និងលើកដាក់

-ចរិតលក្ខណៈនៃចរាចរ ។

តំបន់ និងផ្លូវសំរាប់ធ្វើចរាចរ ត្រូវតែរក្សាឱ្យបាននូវភាពមិនមានការទើសទែង ។

ផ្ទៃដីរបស់ផ្លូវ ត្រូវមានភាពជាប់មាំសមស្រប រលីងល្អ មិនមានរណ្តៅ ទួលរដិបរដុប និងមិនត្រូវមានជំរាលចោទហួសប្រមាណ ។

ត្រូវដាក់ផ្លាកសញ្ញាតាមច្បាប់ចរាចរនិងសន្តិសុខ ងាយឱ្យកម្មករបានយល់ មានលក្ខណៈសាមញ្ញ និងខ្លី ។ ផ្លាកសញ្ញានេះ ត្រូវធ្វើការសំអាត និងថែរក្សាឱ្យបានល្អជាទៀងទាត់ ។

**សំភារៈនិងប្រដាប់ប្រដាធ្វើការនៅវាលដែលចាំបាច់**

ពន្លាក កាំបិត កណ្តៀវ និង ឧបករណ៍មុតគ្រប់ប្រភេទ ត្រូវដាក់នៅក្នុងស្រោម ឬចង្កឹសំរាប់ការពារ ។

**ប្រការ៤._ រោងចក្រសំរាប់ធ្វើប្រព្រឹត្តកម្មនិងរូបបរិវត្តន៍**

**ហានិភ័យគីមី**

-សារធាតុ និងធាតុផ្សំគីមី ដែលប្រើប្រាស់នៅក្នុងចំការដំណាំ ត្រូវរៀបចំទុកដាក់នៅក្នុងកន្លែងដែលនិយោជកសាងសង់ដោយមាំទាំល្អ មានកំរាលចាក់ស៊ីម៉ង់ត៍ ឬការពារទុកនៅក្នុងធុងដែលស្ងួត មានខ្យល់ចេញចូល និងចាក់សោជាប់ជានិច្ច ។-

3

ទីកន្លែងទាំងនោះ ត្រូវមានសម្ភារៈសមស្រប សំរាប់បង្ការទប់ទល់នឹងអគ្គីភ័យផង ។

-ធុង សំបកចាវ កញ្ចប់ដែលផ្ទុកវត្ថុធាតុទាំងនោះ ត្រូវមានសរសេរអក្សរជាភាសាដែលកម្មករនិយោជិតអាចមើលយល់និងកំណត់បាន នូវឈ្មោះនិងធាតុដើមនៃសារធាតុឬធាតុផ្សំ គ្រោះថ្នាក់ក្នុងការប្រើ ការប្រុងប្រយ័ត្ននៅពេលប្រើប្រាស់វា ។

-អធិការពេទ្យការងារ អាចសុំឱ្យនិយោជកតម្លើងកន្លែងលាងទឹកសំអាតបន្ទាន់ កាលបើប្រភេទនៃផលិតផលដែលគេប្រើ មានភស្តុតាងសមស្រប គួរឱ្យមាន ។

-និយោជក ត្រូវចាត់នូវវាលវិធានការចាំបាច់ដើម្បីបង្ការហានិភ័យនានា ដែលកើតឡើងដោយ ការហៀរ លេច ការខ្ចាត ឬសាច ការធ្លាក់ចូលក្នុងធុង ប្រឡាយបង្ហូរ និងបណ្តាញប្រឡាយចំហ ដែលអាចមានសារធាតុ ឬធាតុផ្សំគីមី ដែលគេប្រើប្រាស់ក្នុងការងារប្រព្រឹត្តកម្មនិងធ្វើរូបបរិវត្តន៍។

-កាលណាការប្រើប្រាស់សារធាតុ ឬធាតុផ្សំគីមី អាចនាំឱ្យមានគ្រោះថ្នាក់ដល់កម្មករនិយោជិត និយោជកត្រូវបង្កើតឱ្យមានសលាកប័ត្រសន្តិសុខសំរាប់សារធាតុគីមី ឬធាតុផ្សំគីមីនីមួយ១ ។ សលាកប័ត្រនេះ យ៉ាងហោចណាស់ត្រូវមានការបង្ហាញអំពី :

-អត្តសញ្ញាណនៃផលិតផលតាមទីផ្សារ

-លក្ខណៈរូប លក្ខណៈគីមី និងលក្ខណៈពិសេស នៃជាតិពុលរបស់វា

-ការប្រុងប្រយ័ត្នចំពោះការស្តុកទុក ការប្រើប្រាស់ និងការកាន់ ឬលាយ ព្រមទាំងការបំផ្លាញ ឬបោះបង់ចោល

-ការចាត់វិធានការពេលមានគ្រោះថ្នាក់ ។

និយោជក ត្រូវបញ្ជូនសលាកប័ត្រសន្តិសុខទៅឱ្យពេទ្យការងារ ។

**ប្រការ៥.. ហានិភ័យមេកានិច**

គ្រឿងម៉ាស៊ីន គ្រឿងយន្ត បរិធានបញ្ជូន និងប្រដាប់ប្រដានានា ត្រូវតម្លើង និងរៀបចំក្នុងស្ថានភាពល្អសមរម្យប្រកបដោយសុវត្ថិភាព ។

**សំភារៈចល័តរបស់គ្រឿងម៉ាស៊ីន និងឧបករណ៍បញ្ជា**

-បីយែលនិងស្លាបកង្ហារម៉ូទ័រ កង់យោង ដងត្រង់ស្មីស្យុង ស្ពឹចក្រកោណ ឬស៊ីឡាំង ត្រូវមានប្រដាប់ការពារ ឬដាក់ឆ្ងាយផុតពីដៃកម្មករនិយោជិត ។

-សំភារៈចល័តដទៃទៀតរបស់ម៉ាស៊ីន ត្រូវមានប្រដាប់ការពារ ។ ដូចគ្នានេះដែរ ចំពោះខ្សែពាន ឬខ្សែកាបដែលឆ្លងកាត់ទីទំនៃរោងជាង ឬក៏រត់លើពូលីត្រង់ស្មីស្យុង ត្រូវដាក់ឱ្យបានកំពស់យ៉ាងតិចពីរម៉ែត្រពីដី។

-បរិធានបន្ទាប់បន្សំនៃម៉ាស៊ីន ឬបរិធានប្រើប្រាស់របស់បុគ្គលិក ត្រូវការពារពីការប៉ះពាល់ដល់ខ្សែពានដែលកំពុងដំណើរការ ។

-ម៉ាស៊ីនសង្កត់គ្រប់ប្រភេទ ដែលដើរដោយប្រព័ន្ធមេកានិចស្វ័យប្រវត្តិ ត្រូវរៀបចំ ការពារ បញ្ជា ឬប្រើប្រាស់យ៉ាងណា ឱ្យយន្តការីទាំងឡាយ អាចដកចេញទាន់ នូវគ្រឿងប្រដាប់នៃការងារមានចលនាទាំងនោះ ។

-ក្នុងករណីនៃការជួសជុលម៉ាស៊ីនសង្កត់មេកានិចសាមញ្ញ ឬក៏គ្រឿងប្រដាប់ការពារសំរាប់ការបញ្ជា ឬការប្រើប្រាស់។

ណាមួយ រាល់ការបញ្ឈប់ម៉ាស៊ីន ត្រូវធានាឱ្យបាននូវការកាត់ផ្តាច់ទំនាក់ទំនងរវាងម៉ាស៊ីន និងកម្លាំងដែលនាំឱ្យមានចលនា និងត្រូវធានាថា ប្រភេទការងារនេះនឹងមិនរាំងស្ទះដោយការតាមអំប្រើយ៉ា ឬស្នាបចក្រ ព្រមទាំងគូលិស្ស (ប្រឡាយលកតូចៗ) ប្រសិនបើមានប៉ះពាល់ដល់គ្រឿងទាំងនេះ ។ ត្រូវធ្វើដូចគ្នានេះដែរ ចំពោះការងារសំអាត និងការដាក់ឱ្យគ្រឿងមេកានិចឈប់ដំណើរការ ។

## ប្រការ៦._ ឋបនកម្មអគ្គិសនី

ឋបនកម្មអគ្គិសនីគ្រប់ផ្នែក ត្រូវរៀបចំឡើងក្នុងគោលបំណងរក្សាបាន នូវកិរិតចំងាយសមរម្យ ដើម្បីធានាដល់សុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិត ព្រមទាំងធានាបង្ការទប់នឹងគ្រោះអគ្គិភ័យនិងការផ្ទុះ ។ ឋបនកម្មអគ្គិសនីត្រូវបង្ហាញឱ្យឃើញនូវភាពជាប់មាំខាងមេកានិច ធៀបទៅនឹងហានិភ័យនៃការបំផ្លាញ នាំឱ្យខូចខាតដែលវាត្រូវប្រឈមជាមួយ ។ ម្យ៉ាងទៀត ឋបនកម្មនេះត្រូវតែស្ថាបនាយ៉ាងណា ដើម្បីឱ្យចរន្តធ្លងកាត់បានធម្មតា មិនធ្វើឱ្យឡើងកំដៅ នាំឱ្យគ្រោះថ្នាក់ដល់ខ្សែចម្លងអ៊ីសូឡង់ ឬវត្ថុផ្សេងៗដែលដាក់នៅជិតនោះ ។

ឋបនកម្មអគ្គិសនី ត្រូវអនុវត្តដោយបុគ្គលិកជំនាញ និងមានប្រើប្រាស់សំភារៈអគ្គិសនីសមស្រប អនុលោមតាមវិធានបច្ចេកទេសអគ្គិសនី ។ ការតម្លើងបន្ថែម ការកែតំរូវ ឬការជួសជុល ត្រូវអនុវត្តតាមលក្ខខណ្ឌដូចគ្នានឹងឋបនកម្មដែរ ។

## ប្រការ៧._ ការរៀបចំទីកន្លែងអគារ

អគារនានាដែលជាទីជម្រកនៃកន្លែងធ្វើការ និងទីកន្លែងទុកបំរុងសំរាប់កម្មករនិយោជិត ជាទូទៅត្រូវមានភាពជាប់មាំនិងមានលំនឹងគ្រប់គ្រាន់សមស្រប និងទប់ទល់បានរាល់ទម្ងន់នៃការប្រើប្រាស់ ។

-ផ្ទៃក្រាលត្រូវតែមានភាពជាប់ នឹងមិនមានរងិបរង៉ុប ថ្នក់ប្រហោង ឬមានផ្ទៃជំរាលដែលអាចបង្កគ្រោះថ្នាក់។ ផ្ទៃក្រាលមិនត្រូវមានភាពរអិលទេ។

-ខឿន ជញ្ជាំង និងពិតាន ត្រូវមានលក្ខណៈសមស្របទៅនឹងសកម្មភាពអនុវត្តការងារ ព្រមទាំងងាយស្រួលលាងសំអាត។

-កំលាតទទឹងផ្លូវ រវាងគ្រឿងបរិក្ខា និងឋបនភ័ណ្ឌនានា ត្រូវមានប្រវែងអប្បបរមា ០.៨ ម៉ែត្រ។

-ស្ពានធ្នងតូចៗ ឬស្នូរ ឬ្ចតហ៊្រិម ព្រមទាំងមធ្យោបាយសំរាប់ចេញចូលទៅទីទាំងនោះ ត្រូវតែស្ថាបនា តម្លើង ឬការពារយ៉ាងណា ធានាបាននូវសុវត្ថិសុខដល់កម្មករនិយោជិត។

-អគារនានា ដែលជាទីជម្រកនៃកន្លែងធ្វើការ និងទីកន្លែងទុកបំរុងសំរាប់កម្មករនិយោជិត ត្រូវមានការថែទាំឱ្យបានត្រឹមត្រូវនិងជាប្រចាំ ព្រមទាំងគ្មានហានិភ័យ។

-ការបំភ្លឺនៅទីកន្លែងធ្វើការ កន្លែងបំរុងសំរាប់កម្មករនិងទីកន្លែងពាក់ព័ន្ធនានា ត្រូវរៀបចំដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសលេខ ៤៨៤ ស.ក.ប.យ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពី ពន្លឺនិងការបំភ្លឺ។

-គ្រឿងប្រដាប់បញ្ចេញបញ្ចូលខ្យល់ និងការសំអាតកន្លែងធ្វើការ ត្រូវរៀបចំដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសលេខ ១២៥ ស.ក.ប.យ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបញ្ចេញបញ្ចូលខ្យល់និងការ សំអាតបរិយាកាស។

-កៅអីអង្គុយសំរាប់កម្មករនិយោជិត ត្រូវរៀបចំដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៥៣ ស.ក.ប.យ ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីកៅអីអង្គុយនៅប៉ុស្តិ៍ការងារ។

**ប្រការ៨.-** អនាម័យ

**បង្គន់និងបន្ទប់ទឹក**

ត្រូវតម្លើង និងថែទាំដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៥២ ស.ក.ប.យ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការរៀបចំបង្គន់អនាម័យ ។

**ថតទូសំរាប់ឯកសណ្ឋាន និងកន្លែងទុកសម្លៀកបំពាក់**

និយោជក ត្រូវផ្តល់ថតទូសំរាប់កម្មករនិយោជិត ម្នាក់១ដាច់ដោយឡែកពីគ្នា។ ថតទាំងនោះត្រូវបិទចាក់សោ ដែលត្រូវទុកសំរាប់ដាក់ប្រដាប់ប្រដាផ្ទាល់ខ្លួន លើកលែងតែផលិតផលដែលឆាប់ខូច ឬចំណីអាហារ ។

បទបញ្ជាផ្ទៃក្នុង អាចបញ្ជាក់អំពីលក្ខខណ្ឌនានា ទាក់ទងនឹងការទុកបំរុង ការប្រើប្រាស់ និងការថែរក្សាថតទូទាំងនោះ ។

និយោជក ត្រូវរៀបចំឱ្យមានកន្លែងទុកសម្លៀកបំពាក់សំរាប់កម្មករនិយោជិត។ កន្លែងទុកសម្លៀកបំពាក់នេះត្រូវនៅផ្សេងពីកន្លែងធ្វើការ ហើយត្រូវមានលក្ខណៈទូលាយសមរម្យ និងមានខ្យល់ចេញចូលបានត្រឹមត្រូវ ។ កន្លែងទុកសម្លៀកបំពាក់ ត្រូវរៀបចំដាច់ដោយឡែកពីគ្នា រវាងកម្មករនិយោជិតភេទប្រុស និងភេទស្រី។

សម្លៀកបំពាក់ ដែលទុកនៅកន្លែងទុកនោះត្រូវស្ងួត។ សម្លៀកបំពាក់សំរាប់ការងារ ឬសំរាប់ការពារដែលបានប្រើនៅក្នុងរោងចក្រ ត្រូវដាក់ឱ្យឃ្លាតឆ្ងាយពីសម្លៀកបំពាក់ផងទៃ ដើម្បីចៀសវាងការប្រឡាក់។

**អាហារដ្ឋាន និងភោជនីយដ្ឋាន**

ការទទួលទានអាហារនៅកន្លែងធ្វើការ ត្រូវហាមឃាត់ ។

និយោជកមានកាតព្វកិច្ចរៀបចំឱ្យមានភោជនីយដ្ឋាន ឬអាហារដ្ឋានស្របទៅតាមតំរូវការចាំបាច់។ ការកសាងអាហារដ្ឋាន ឬភោជនីយដ្ឋានទាំងនេះ ត្រូវធ្វើដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាស ស្តីពីសេវាសង្គម សំរាប់កម្មករនិយោជិត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ការផ្តល់ភេសជ្ជៈអនាម័យដល់កម្មករនិយោជិត ត្រូវធ្វើដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៥៤ ស.ក.ប.យ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ។

**ប្រការ៩.-** **លក្ខខណ្ឌជីវភាព**

**ទឹក**

ភូមិនីមួយៗ ត្រូវផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ យ៉ាងហោចណាស់ ក៏មាននៅកន្លែងចែកចាយអាហារ ។ ទីកន្លែងសំរាប់ចែកចាយទឹក ត្រូវរៀបចំនិងការពារពីហានិភ័យដោយការហៀរ ការហូរចូល ការសាច និងការស្ក ដោយផ្ទាល់ ឬប្រយោលនៃរូបធាតុនានា នាំឱ្យប៉ះពាល់ដល់គុណភាពទឹកស្អាត។ កន្លែងសំរាប់ចែកចាយទឹកត្រូវប្រើចំពួយរូបីណេ ដើម្បីបានលក្ខខណ្ឌអនាម័យបានល្អ ។

-ការងាររៀបចំចាត់ចែង ដើម្បីបានគុណភាពទឹកស្អាត និងការចែកចាយទឹក គឺជាភារកិច្ចរបស់និយោជក។

និយោជក ត្រូវបង្ហាញនូវវិញ្ញាបនប័ត្រនៃការវិភាគទឹកដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមការស្នើសុំរបស់ផ្នែកអធិការកិច្ចការងារ ។ ការវិភាគទឹកនេះ ត្រូវតែធ្វើឱ្យបានញឹកញាប់តាមដែលអាចធ្វើបាន ។

-ទីកន្លែងដែលមានទឹកដក់ នៅក្នុងភូមិ ឬទីជិតភូមិដែលអាចជាជម្រកសត្វដង្កូវ ត្រូវលប់បំបាត់ចោល ។ ទីកន្លែងដែលមានទឹកដក់នៅជិតលំនៅដ្ឋាន ត្រូវលប់បំបាត់ដោយអ្នករស់នៅទីនោះដោយខ្លួនឯង ។

-និយោជក មានភារកិច្ចលប់បំបាត់ទីកន្លែងដែលមានទឹកដក់នៅតាមទីសាធារណៈ និងកន្លែងសម្ហូភាពបុំណ្ណោះ ។

**កន្លែងរក្សាក្មេង**

និយោជក ត្រូវផ្តល់ដោយឥតគិតថ្លៃចំពោះកម្មករនិយោជិត នូវកន្លែងរក្សាក្មេងមួយ នៅតាមភូមិនីមួយៗ ដែលកន្លែងនេះ ត្រូវស្ថិតនៅជិតលំនៅស្ថាន ដើម្បីទទួលក្មេងៗពីឪពុកម្តាយចាប់ពីពេលចូលធ្វើការនៅពេលព្រឹក រហូតដល់ពេលពួកគេវិលត្រឡប់មកក្នុងភូមិវិញ ។

-ទីតាំងកន្លែងរក្សាក្មេង ត្រូវមានលក្ខណៈទូលាយសមល្មម មានខ្យល់ចេញចូលត្រឹមត្រូវ អាចទទួលការបំភ្លឺតាមធម្មជាតិ និងអាចមើលឃើញទៅទីខាងក្រៅបាន ។ ទីកន្លែងទាំងនេះ ត្រូវរៀបចំយ៉ាងណាកុំឱ្យមានមូស ។

-ផ្ទៃក្រាល និងជញ្ជាំង ត្រូវមានលក្ខណៈងាយស្រួលក្នុងការបោសសំអាត និងរំងាប់មេរោគ ។ កន្លែងរក្សាក្មេង ត្រូវមានសភាពស្អាតជានិច្ច និងយ៉ាងហោចណាស់ត្រូវបោសសំអាតម្តងក្នុងមួយថ្ងៃ ។

**និយោជក ត្រូវពិនិត្យមើលដើម្បីឱ្យកន្លែងរក្សាក្មេងមាន :**

-ទឹកប្រកបដោយអនាម័យ

-សំភារៈសំរាប់ចំអិន និងប្រដាប់ប្រដាសំរាប់ផ្ទះបាយដែលចាំបាច់ ដើម្បីរៀបចំអាហារដល់ក្មេង

-គ្រឿងសង្ហារិមសមស្រប

-មធ្យោបាយប្រើប្រាស់សំរាប់ងូតទឹក

-ចំណីអាហារស្របតាមស្ថានភាព និងអាយុក្មេង

-សំភារៈផ្លាស់ប្តូរ និងដុះលាង

-ប្រដាប់លេង ប្រដាប់បង្កើនបញ្ញា និងប្រដាប់សំរាប់អប់រំ ។

និយោជក មានភារកិច្ចផ្តល់នូវកិច្ចការសព្វបែបយ៉ាងដែលចាំបាច់ សំរាប់ការរក្សាក្មេងៗដែលមានអាយុតិចជាង១២ ឆ្នាំ ជាកូនរបស់កម្មករនិយោជិតរបស់ខ្លួន ដោយត្រូវផ្តល់ឱ្យមានបុគ្គលិកជំនាញដល់កន្លែងរក្សាក្មេង ឬសាលារៀន ហើយដែលមិនត្រូវឱ្យក្មេងមានវត្តមាននៅពេលម៉ោងធ្វើការ ឬនៅកន្លែងធ្វើការនៃឪពុកម្តាយរបស់វាឡើយ ។

**ប្រការ១០.- សេវាកម្មវេជ្ជសាស្ត្រ**

សេវាកម្មវេជ្ជសាស្ត្រ ត្រូវឆ្លើយតបទៅតាមបែបបទនៃការបង្កើតនិងការប្រព្រឹត្តទៅ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្មសេវាពេទ្យសហគ្រាស

**ប្រការ១១.- បទប្បញ្ញត្តិទាក់ទងនឹងកម្មករនិយោជិតស្ត្រី និង ក្មេងជំទង់**

ក្មេងទាំងពីរភេទ ដែលមានអាយុតិចជាង ១៨ឆ្នាំ ត្រូវហាមមិនឱ្យធ្វើការនៅក្នុងរោងចក្រធ្វើប្រព្រឹត្តកម្ម និងរូបបរិវត្តន៍ ។

លក្ខខណ្ឌនៃការលើក លី សែង របស់ស្ត្រី និងក្មេងអាយុតិចជាង ១៨ឆ្នាំ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ១២៤ ស.ក.ប.យ ចុះថ្ងៃទី ១៥ ខែ មិថុនា ២០០១ ស្តីពីការលើកដាក់ទំងន់ដោយកំលាំងពលកម្ម ។

**ប្រការ១២.- សេវាកម្មរដ្ឋបាល**

ចំពោះបញ្ហាអនាម័យ និងសុវត្ថិភាពសំរាប់បុគ្គលិកនៅក្នុងសេវាកម្មរដ្ឋបាល គឺត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនានា ដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារ និងអត្ថបទណែនាំអនុវត្តច្បាប់នេះ ។

**ប្រការ១៣.-**

ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុង ជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១៤.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ឆន សុភ**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា "ដើម្បីអនុវត្ត"
- សហភាពសហព័ន្ធសហជីព "ដើម្បីជូនជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ...៣០៧.....កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ៥ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពីលក្ខខណ្ឌអនាម័យ និងសន្តិសុខការងារ
## ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-**

ដោយមិនគិតដល់បទប្បញ្ញត្តិនៃប្រកាសផ្សេងៗដទៃទៀតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជកនៃសហគ្រាស គ្រឹះស្ថានកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់ លើលក្ខខណ្ឌការងារឱ្យមានសុវត្ថិភាព និងមានអនាម័យឧស្សាហកម្មត្រឹមត្រូវ ។

**ប្រការ ២.- រោងជាង ឬការដ្ឋានការងារ**

និយោជកត្រូវរៀបចំស្ថានភាពនៃរោងជាង ឬផ្នែកផលិតកម្មនីមួយៗឱ្យបានសមស្របទៅតាមការងារ ចំនួន-

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខណ្ឌទួលគោក.ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៥៣ ៥៣៨

មនុស្ស និងបរិស្ថានជុំវិញ។

- សម្ភារៈការងារ និងសម្ភារៈការពារ ត្រូវមានសភាពសមស្រប មាំទាំ មានប្រសិទ្ធិភាព មិនបង្កឱ្យមានការលំបាក ឬបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើ ឬអ្នកនៅជិតខាង។

- និយោជកត្រូវខណ្ឌចែករោងជាងដែលមានការងារខុសៗគ្នា ឱ្យនៅដាច់ពីគ្នា ដើម្បីជៀសវាងការ រំខានដោយសារបរិយាកាស សំឡេង ក្លិន ឬធូលីផ្សេងៗ។

- និយោជកត្រូវរៀបចំការបញ្ចូលវត្ថុធាតុដើម ខ្សែសង្វាក់ផលិតកម្ម ការបញ្ចេញផលិតផលសំរេចឱ្យមានរបៀបរៀបរយ ធានាបាននូវសណ្តាប់ធ្នាប់ល្អក្នុងរោងជាង។

- រោងជាងដែលមានប្រើប្រពន្ធ័ចំហាយទឹកបន្តតាមទុយយោរ៉ព័ទ្ធដោយសារធាតុអាមីញ៉ង់ ត្រូវខណ្ឌដាច់ពីគេហើយត្រូវចាត់អ្នកឃ្លាំមើលប្រព័ន្ធនេះជាប្រចាំ និងត្រូវចាត់វិធានការចាំបាច់ជាបន្ទាន់នៅពេលមានបញ្ហា។

## ប្រការ ៣._ ឃ្លាំងស្តុកសន្និធិ

ឃ្លាំងស្តុកសន្និធិសម្រាប់រោងចក្រ សហគ្រាសនីមួយៗ ត្រូវខណ្ឌចែកជា២យ៉ាងតិច គឺ :

- ឃ្លាំងស្តុកសន្និធិសារធាតុគីមី ត្រូវរៀបចំដាច់ដោយឡែក។ ឃ្លាំងស្តុកសន្និធិសារធាតុគីមីនេះ ត្រូវមានប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវ មិនត្រូវពន្លឺត្រង់នៃព្រះអាទិត្យ និងត្រូវមានប្រព័ន្ធការពារចាំបាច់ផ្សេងៗទៀត សម្រាប់ទប់ទល់នឹងការបង្កឱ្យមានការប្រែរូបភាព ការបែកធ្លាយ ហូរចេញ ឬការបង្កឱ្យផ្ទុះឆេះ ជាដើម។

- ជាលក្ខណៈបណ្តោះអាសន្ន សារធាតុគីមីនីមួយៗ ទោះបានមកពីប្រភពណាក៏ដោយ ត្រូវមានសរសេរឈ្មោះគីមីជាភាសាឡាតាំងបិទភ្ជាប់នឹងដប ឬកំប៉ុងសារធាតុគីមីនោះ។ ម៉្យាងទៀតនិយោជកត្រូវមានឯកសារអធិប្បាយពីសារធាតុគីមីនីមួយៗជាភាសាបារាំង ឬអង់គ្លេស សម្រាប់មន្ត្រីមានសមត្ថកិច្ចត្រួតពិនិត្យនៅពេលចាំបាច់គ្រប់ពេល។

- សម្រាប់ឃ្លាំងស្តុកសន្និធិសម្ភារៈផលិតកម្មផ្សេងដទៃទៀត ក៏ត្រូវរៀបចំយ៉ាងណាឱ្យមានប្រពន្ធ័បញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវដែរ និងធានាឱ្យប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់នោះ ត្រូវបានជួសជុលជាបន្ទាន់បើមានខូច។

- ស្បែក កៅស៊ូ ឬក្រណាត់ត្រូវទទួលស្តុកទំនិញទាំងនេះមួយរយៈឱ្យបាត់ក្លិន ធូលី ឬកំដៅសិនចាំយកមកប្រើសម្រាប់ការងារផលិតកម្ម។

- សញ្ញាការសុខភាពសុវត្ថិភាព និងបទបញ្ជាឃ្លាំងត្រូវបានសរសេរ និងដាក់ឱ្យបានត្រឹមត្រូវតាមទីកន្លែងងាយអាន ងាយយល់ និងថែរក្សាឱ្យនៅស្អាតជានិច្ច។

## ប្រការ ៤._ ការប្រើប្រាស់សារធាតុគីមី

សារធាតុគីមីទាំងឡាយ ដែលមានប្រើក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងគ្រប់ម៉ូ

២

ប្រភេទ រួមមាន:

- ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ មានប្រើសារធាតុគីមីសម្រាប់ការងារផលិតកម្មគ្រប់ប្រភេទ ដូចជា (Hydrocarbures halogénés, Hydrocarbures aliphatiques et acycliques, Alcools, Acétates, Glycols......)

- ក្នុងរោងចក្រដេរស្បែកជើងមានប្រើសារធាតុគីមី ដូចជាការបិតគ្រប់ប្រភេទ ឬថ្នាំលាបស្បែកជាដើម (Sels de chrome, P.V.C, Isocyanates, Cétone, Acétate d'éthyle, Acrylate de méthyle.....) ។

ដើម្បីសុវត្ថិភាពសម្រាប់កម្មករនិយោជិតទូទៅ និងជាសាធារណៈផង និយោជកត្រូវ:

- បណ្តុះបណ្តាលបុគ្គលិកប្រើប្រាស់សារធាតុគីមីឱ្យបានត្រឹមត្រូវជាមុន មុននឹងប្រើគេឱ្យធ្វើការ

- ធានាថាសារធាតុគីមីទាំងអស់ត្រូវបានប្រើតែក្នុងមណ្ឌលខណ្ឌដាច់ដោយឡែក មិនសាយភាយទៅកន្លែងដទៃ

- រៀបចំប្រព័ន្ធបឺតខ្យល់ចេញក្រៅដោយធ្វើយ៉ាងណាធានាឱ្យខ្យល់ដែលបញ្ចេញទៅនោះមិនប៉ះពាល់ ដល់បរិស្ថានសាធារណៈ

- ធានាថាអ្នកធ្វើការជាមួយសារធាតុគីមី មានសម្ភារៈការពារគ្រប់គ្រាន់ និងមានប្រសិទ្ធិភាព

- ត្រូវគ្រោងឱ្យហើយជាស្រេចនូវច្រករត់ចេញ ពិសេសសម្រាប់ប្រើនៅពេលមានអាសន្ន

- សញ្ញាការសុខភាព សុវត្ថិភាព និងបទបញ្ជាការងារ ត្រូវបានសរសេរជាអក្សរខ្មែរ និងដាក់ឱ្យបានត្រឹមត្រូវតាម ទីកន្លែង ងាយអាន ងាយយល់ និងថែរក្សាឱ្យនៅស្អាតជានិច្ច ។

## ប្រការ ៥.- ការអប់រំសុវត្ថិភាពការងារដល់កម្មករនិយោជិត

និយោជកនៃគ្រប់សហគ្រាស រោងចក្រ សិប្បកម្មកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង មានកាតព្វកិច្ចធ្វើការអប់រំជាចាំបាច់ ដល់កម្មករនិយោជិត និងតំណាងរបស់ពួកគេ អំពីអនាម័យ សន្តិសុខការងារ និងអំពីបញ្ហាសុខភាព ដែលមាន ទាក់ទងដល់កិច្ចការនៅតាមប៉ុស្តិ៍ការងារនីមួយៗ ។

* ការអប់រំនេះនិងពន្យល់ប្រាប់ទៅកម្មករនិយោជិតអំពី:
  - ហានិភ័យដែលបង្កឡើងដោយកត្តារូបធាតុ (កំដៅ សំឡេង ពន្លឺ កាំរស្មី រំញ័រ ។ល។)
  - ហានិភ័យនៃសារធាតុគីមី ជីវសាស្ត្រ មេកានិក អគ្គិសនី អគ្គិភ័យ
  - ហានិភ័យដែលអាចនឹងមានដោយសារការងារនៅពេលយប់ ជាដើម
  - វិធានការពារមានប្រសិទ្ធិភាព
  - កាយវិការ អាកប្បកិរិយានៅពេលមានអាសន្ន នៅពេលជួយសង្គ្រោះ
* ការអប់រំនេះត្រូវចាប់ផ្តើមនៅពេល :
  - ចូលធ្វើការដំបូង
  - ប្តូរប៉ុស្តិ៍ការងារ

៣

- ប្តូរបច្ចេកទេសផលិត ប្តូរគ្រឿងយន្ត ឬការបញ្ចូលវត្ថុធាតុថ្មី
- កម្មករនិយោជិតបានឈប់សម្រាកការងាររយៈពេលយូរ (លើសពីមួយខែ) ។

* ការអប់រំនេះត្រូវធ្វើដោយអ្នកបច្ចេកទេសពិតប្រាកដ និងធ្វើក្នុងម៉ោងធ្វើការ ហើយកម្មករនិយោជិតដែលជាសិក្ខាកាមត្រូវបានទទួលប្រាក់ឈ្នួលធម្មតា ។

**ប្រការ ៦.– សម្លៀកបំពាក់ការងារ**

និយោជកត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់២សម្រាប់យ៉ាងតិចក្នុង ១ឆ្នាំ ។ សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង ។ សម្លៀកបំពាក់ ១សម្រាប់ៗ ត្រូវមាន២ផ្នែកយ៉ាងតិច គឺសំពត់ឬខោ ហើយនិងអាវ ដែលមានទំហំស្របនិងខ្លួនប្រាណ ព្រមទាំងសកម្មភាពការងាររបស់កម្មករនិយោជិត ។ សម្រាប់ការងារនៅតាមរោងជាងជួសជុល ការងារនៅកន្លែងប៉ះ ពាល់សារធាតុគីមី ឬការងារនៅក្នុង អាហារដ្ឋានរោងចក្រ និយោជកត្រូវផ្តល់បន្ថែមនូវអាវអៀម ឬប្លូមួយសម្រាប់ទៀត ។ និយោជកត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូជាដើម ។

បទបញ្ជាផ្ទៃក្នុងអាចកំណត់ពីលក្ខខណ្ឌដែលសម្លៀកបំពាក់នេះត្រូវបែងចែក ប្រើប្រាស់ និងថែទាំ ។

**ប្រការ ៧.– ការងារសម្រាប់ស្ត្រី និងកុមារ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារអ្វីទាំងអស់ក្នុងសហគ្រាស រោងចក្រ សិប្បកម្មកាត់ដេរសម្លៀកបំពាក់និងដេរស្បែកជើង ។

កុមារអាយុចាប់ពី ១៥ឆ្នាំឡើងទៅ រហូតក្រោម ១៨ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារមួយចំនួន ដែលងាយបង្កគ្រោះថ្នាក់ ដូចជា:

- ការងារនៅក្នុងរោងជាងជួសជុល
- ការងារប៉ះពាល់សារធាតុគីមី
- ការងារនៅផ្នែកវាយឡេវ ,ផ្នែកកាត់ ផ្នែកបាញ់ខ្សាច់ ផ្នែកក្រឡុក និងសម្ងួត
- ផ្នែកបាញ់ថ្នាំ និងសម្ងួត ផ្នែកខ្សែទឹកហូរ

ចំពោះស្ត្រីមានផ្ទៃពោះចាប់ពីបីខែឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារណាដែលមិនប៉ះពាល់សារធាតុគីមី និង ការងារស្រាលៗ ប៉ុណ្ណោះ ។

**ប្រការ ៨.– សេវាសុខភាព**

និយោជកនៃសហគ្រាស រោងចក្រ សិប្បកម្មកាត់ដេរសម្លៀកបំពាក់និងដេរស្បែកជើងទាំងអស់ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករនិយោជិតរបស់ខ្លួន ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៥ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្មសេវាពេទ្យសហគ្រាស ។

**ប្រការ ៩.-**

ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**វង សូត**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ "**ដើម្បីជូនជ្រាប**"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង
  "**ដើម្បីផ្សព្វផ្សាយ និងអនុវត្ត**"
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា "**ដើម្បីអនុវត្ត**"
- សហព័ន្ធសហជីព "**ដើម្បីជូនជ្រាប**"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "**ដើម្បីជួយផ្សព្វផ្សាយ**"
- កាលប្បវត្តិ និងឯកសារ

៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខៈ ៣០៤.........កប/ប្រ.ក

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៧

**ប្រកាស**
**ស្តីពី**
**លក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសស្រែអំបិល**

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យម្ហូបអាហារសំរាប់មនុស្ស
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>សម្រេច</u>**

**ប្រការ ១.-**

និយោជក គ្រប់សហគ្រាស សិប្បកម្ម ស្រែអំបិលទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ [illegible]ការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់ លើលក្ខខណ្ឌការងារ ដោយ[illegible] រស់នៅដ៏សមរម្យ និងមានអនាម័យត្រឹមត្រូវ ។

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់២ស[illegible]

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខ័ណ្ឌទួលគោក. ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារៈ (០២៣) ៣៥៣ ៥៣៨

សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល ១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ ១ សម្រាប់ៗត្រូវមាន ២ផ្នែក យ៉ាងតិច គឺសំពត់ឬខោ ហើយនិងអាវ ដែលមានទំហំស្របនឹងខ្លួនប្រាណ ព្រមទាំងសកម្មភាពការងាររបស់កម្មករនិយោជិត។ និយោជក ត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូជាដើម។

បទបញ្ជាផ្ទៃក្នុងអាចកំណត់ពីលក្ខខណ្ឌដែលសំលៀកបំពាក់នេះត្រូវបែងចែក ប្រើប្រាស់ និងថែទាំ។

**ប្រការ ៣.- សម្ភារៈការពារបុគ្គល និងសម្ភារៈការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ ដូចជាស្បែកជើង កៅស៊ូកវែង ស្រោមដៃកៅស៊ូ ឬម្ហូកហាមធំជាដើម ។ល។ សម្ភារៈការងារ ដូចជាខ្នោស ដងវែក ខ្សែ ចប រនាស់ជាដើម ត្រូវមាន សភាពមាំទាំ មិនបង្កឱ្យមានការលំបាក ឬបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។

**ប្រការ ៤.- ភេសជ្ជៈអនាម័យ**

និយោជកនៃសហគ្រាសស្រែអំបិលត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករ និយោជិតរបស់ខ្លួនស្របទៅតាមប្រកាសលេខ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ។

**ប្រការ ៥.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម**

ការលើកដាក់ទម្ងន់ផ្សេងៗ ជាពិសេសសម្រាប់ស្ត្រីនិងកុមារអាយុក្រោម១៨ឆ្នាំ ត្រូវអនុវត្តឱ្យបានស្របទៅតាមប្រកាសលេខ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម។

**ប្រការ ៦.- ទីតាំងរស់នៅសម្រាប់កម្មករនិយោជិត និងគ្រួសារ**

ក្នុងករណីដែលកម្មករនិយោជិតមកស្នាក់រស់នៅក្នុងការដ្ឋានស្រែអំបិល ទោះដោយមានតែបុគ្គលខ្លួនម្នាក់ឯង ឬជាគ្រួសារ ទាំងមូលក៏ដោយ និយោជកមានកាតព្វកិច្ចរៀបចំឱ្យមានវាសនដ្ឋាន សម្រាប់កម្មករ និយោជិតគ្មានគ្រួសារនៅផ្សេង ហើយកម្មករនិយោជិតដែលមានគ្រួសារស្នាក់នៅតាមគ្រួសារនីមួយៗដោយឡែក។ ការរៀបចំវាសនដ្ឋាននេះត្រូវធ្វើឱ្យស្របនឹងប្រកាសស្តីពីការរៀបចំវាសនដ្ឋានសម្រាប់កម្មករនិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៧.- ការងារសម្រាប់ស្ត្រី និងកុមារ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារអ្វីទាំងអស់ក្នុងការដ្ឋានស្រែអំបិល ទោះដោយថា ជាការជួយការងារ ឪពុកម្តាយក៏ដោយ។

កុមារអាយុចាប់ពីអាយុ១៥ឆ្នាំឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារដែលមិនប៉ះពាល់ដល់សុខភាព សន្តិសុខ និងសីលធម៌ របស់កុមារទាំងនោះ។

ចំពោះស្ត្រីដែលមានផ្ទៃពោះ ចាប់ពីបីខែឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារស្រាលៗប៉ុណ្ណោះ ។៕

២

**ប្រការ ៨.- សេវាសុខភាព**

និយោជក នៃសហគ្រាស សិប្បកម្មស្រែអំបិល ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករនិយោជិតរបស់ខ្លួនស្របនឹង ប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៥ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌនិងបេសកកម្មសេវាពេទ្យសហគ្រាស ។

**ប្រការ ៩.-**

ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា "ដើម្បីអនុវត្ត"
- សហព័ន្ធសហជីព "ដើម្បីជូនជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ

រដ្ឋមន្ត្រី

**វង សុត**

៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខៈ ៣០៩ ......កប / ប្រ-ក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៧

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

និយោជក នៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវ យកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់លើលក្ខខណ្ឌការងារឱ្យមានសុវត្ថិភាព និងជីវភាព រស់នៅ ដ៏សមរម្យ មានអនាម័យត្រឹមត្រូវ

១

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខណ្ឌទួលគោក. ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារៈ (០២៣) ៣៩៣ ៥៣៨

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់២សម្រាប់ ក្នុង១រដូវ/ឆ្នាំ។ សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ ១សម្រាប់ៗ ត្រូវមាន ២ផ្នែកយ៉ាងតិច គឺ សំពត់ឬខោ ហើយនិងអាវ ដែលមានទំហំស្របនិងខ្លួនប្រាណ ព្រមទាំង សកម្មភាពការងារ របស់កម្មករនិយោជិត។ និយោជក ត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូជាដើម ។

បទបញ្ជាផ្ទៃក្នុង អាចកំណត់ពីលក្ខខណ្ឌដែលសម្លៀកបំពាក់នេះត្រូវបែងចែកប្រើប្រាស់ និងថែទាំ។

**ប្រការ ៣.- សម្ភារៈការពារបុគ្គល និងសម្ភារៈការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ដូចជា ស្បែក ជើង ស្រោមដៃ ឬម៉ូកជាដើម ។ល។

សម្ភារៈការងារដូចជា រទេះដឹកជញ្ជូនដីឬឥដ្ឋ ចប ពូថៅជាដើម ត្រូវមានសភាពមាំទាំ មិនបង្កឱ្យមានការលំបាកឬបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ឬអ្នកនៅជិតខាង។ ម៉ាស៊ីនកិនដីឥដ្ឋ ផលិតឥដ្ឋត្រូវរៀបចំយ៉ាងណាឱ្យមានសុវត្ថិភាព ដល់អ្នកធ្វើការ ដូចជាត្រូវមានបង្កាន់ដៃសម្រាប់តោងឬទប់កុំឱ្យរអិល តំរបម៉ាស៊ីនជាដើម។

មុននឹងអនុញ្ញាតឱ្យកម្មករនិយោជិតចូលទៅធ្វើក្នុងឡ ទោះនៅពេលជញ្ជូនឥដ្ឋចូលឬចេញក៏ដោយ និយោជក ត្រូវ រកគ្រប់មធ្យោបាយធ្វើយ៉ាងណា ឱ្យឡមានសីតុណ្ហភាពធម្មតាសិន (មិនឱ្យលើសពី៣៧អង្សាសេ)។

**ប្រការ ៤.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម-ការរៀបចំបង្គន់អនាម័យ-ការផ្តល់គេសជ្ជៈអនាម័យ**

និយោជកនៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវប្រកាសៈ

- លេខ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម
- លេខ០៥២ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការរៀបចំបង្គន់អនាម័យ
- លេខ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការផ្តល់គេសជ្ជៈអនាម័យ ។

**ប្រការ ៥.- ទីតាំងរស់នៅសម្រាប់កម្មករនិយោជិតនិងគ្រួសារ**

ក្នុងករណីដែលកម្មករនិយោជិតមកស្នាក់នៅក្នុងសហគ្រាស សិប្បកម្មឡឥដ្ឋ ទោះដោយបុគ្គលខ្លួនម្នាក់ឯង ឬជា គ្រួសារ ទាំងមូលក៏ដោយ និយោជកមានកាតព្វកិច្ចរៀបចំឱ្យមាន វាសនដ្ឋានសម្រាប់កម្មករនិយោជិតគ្មានគ្រួសារ នៅផ្សេង ហើយកម្មករនិយោជិតមានគ្រួសារនៅតាម គ្រួសារនីមួយៗដោយឡែក។ ការរៀបចំវាសនដ្ឋាននេះត្រូវធ្វើឱ្យស្របនឹងប្រកាស ស្តីពីវាសនដ្ឋានសម្រាប់កម្មករនិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៤៨

២

**ប្រការ ៦.- ការងារសម្រាប់ស្ត្រី និងកុមារ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការអ្វីទាំងអស់ក្នុងការដ្ឋានឡឥដ្ឋ ទោះដោយថាជាការជួយឪពុកម្តាយ ក៏ដោយ ។កុមារអាយុចាប់ពី១៥ឆ្នាំឡើងទៅ រហូតក្រោម១៨ឆ្នាំ ត្រូវហាមមិនឱ្យធ្វើការងារមួយចំនួនដែលងាយបង្ក គ្រោះថ្នាក់ ដូចជាការងារពុះអុស ការងារធ្វើដី ច្រូំដី ការងារនៅកន្លែងម៉ាស៊ីនផលិតឥដ្ឋជាដើម ។

ចំពោះស្ត្រីមានផ្ទៃពោះចាប់ពីបីខែឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារស្រាលៗប៉ុណ្ណោះ ។

**ប្រការ ៧.- សេវាសុខភាព**

និយោជក នៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករនិយោជិតរបស់ ខ្លួន ស្របនឹងប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋាន សហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្មសេវាពេទ្យសហគ្រាស ។

**ប្រការ ៨.-**

ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ **"ដើម្បីជូនជ្រាប"**
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង **"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"**
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា **"ដើម្បីអនុវត្ត"**
- សហព័ន្ធសហជីព **"ដើម្បីជូនជ្រាប"**
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ **"ដើម្បីជួយផ្សព្វផ្សាយ"**
- កាលប្បវត្តិ និងឯកសារ

**រដ្ឋមន្ត្រី**

**វង សូត**

៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខៈ ០០២/០៨ កប/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ មករា ឆ្នាំ២០០៧

**ប្រកាស**

**ស្តីពី**

**ការកំណត់ប្រភេទមុខរបរ និងការងារស្រាល ដែលអនុញ្ញាត**
**ឱ្យកុមារអាចធ្វើការងារ ចាប់ពីអាយុ ១២ ដល់ ១៥ឆ្នាំ**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>សម្រេច</u>**

**ប្រការ ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ [illegible] ប្រើប្រាស់កុមារដែលមានអាយុ ១២ឆ្នាំ តែក្នុងប្រភេទការងារស្រាល១ ដូចមានចែងក្នុង [illegible] កុមារដែលត្រូវធ្វើការជាផ្នែកមួយនៃការបណ្តុះបណ្តាលវិជ្ជាជីវៈក៏អាចធ្វើការ [illegible] មានចែងក្នុងប្រការ២ នៃប្រកាសនេះដែរ ។

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខ័ណ្ឌទួលគោក. ប្រអប់សំបុត្រ P.O Box 1506 ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៥៣ ៥៣៨

**ប្រការ ២.-** ការងារស្រាល គឺជាប្រភេទការងារទាំងនោះ មិនបណ្តាលឱ្យខូចសុខភាព ឬការអភិវឌ្ឍន៍នៃចិត្ត និងកាយរបស់កុមារ និងមិនបណ្តាលឱ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ ការចូលរួមក្នុងកម្មវិធីតម្រង់ទិស ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ប្រភេទការងារស្រាលមានជាអាទិ៍:

១) ការងារកសិកម្មស្រាលៗខាងការងារចិញ្ចឹមសត្វ ការងារថែទាំប្រភេទសត្វស្រុកតូចៗ ប៉ុន្តែមិនមែនជាការចាប់និងសម្លាប់នូវប្រភេទសត្វទាំងនោះទេ ការងារដាំកូនឈើ ការងារប្រមូលកសិផល ការងារបេះផ្លែឈើ ប៉ុន្តែមិនមែនឡើងបេះទេ និងការងារបោសសំអាត ។

២) ការងារជំរះស្មៅ និងឈូសឆាយដី

៣) ការងារកត់ត្រាទំនិញ

៤) ការងារនៅតាមហាងលក់ទំនិញមួយចំនួន ដូចជាស្តង់ តូបលក់បន្លែផ្លែឈើ ឬលក់សារព័ត៌មាន និងផលិតផល ប្រហាក់ប្រហែលជាដើម

៥) ការទទួល ការវេចខ្ចប់ ការជ្រើសរើស ការបែងចែកតាមប្រភេទទំនិញផ្សេងៗគ្នា និងការរៀបផ្ទុំរបស់ស្រាលៗ រួមទាំងពន្លា ឬដកទំនិញចេញពីកញ្ចប់

៦) ការបោសសំអាត ការជូតសំអាត និងការរៀបចំតុបាយ ដូចជាដាក់ចាន ស្លាបព្រា សម កាំបិត ជាដើម

៧) ការតំឡើងការងារហត្ថកម្មដែលមានលក្ខណៈងាយស្រួល ប៉ុន្តែមិនមែនជាការងារផ្សារលោហៈធាតុ ផ្សារដែក ឬការងារជាមួយផលិតផលដែលបង្កគ្រោះថ្នាក់នោះទេ

៨) ការងារលាបថ្នាំដោយមានប្រើឧបករណ៍ការពារ ប៉ុន្តែមិនមែនជាការងារបាញ់ថ្នាំពណ៌ទេ

៩) ការងារដែលមានលក្ខណៈងាយស្រួល ដូចជាផ្នែកដេរ ច្រកទំនិញចូលថង់ បត់ក្រដាស់ឡាំង ឬការដុស ខាត់ ជូតកញ្ចក់ និងប្រដាប់ប្រដាធ្វើដោយសេរ៉ាមិច ឬការងារកាត់ព្រុយសំលៀកបំពាក់ ឬការចាប់ផ្ទុំ គ្រប់ផ្នែកផ្សេងៗនៃសម្លៀកបំពាក់ ឬជូតសំអាតភាពកខ្វក់ដែលប្រលាក់ជាប់លើផលិតផលសម្លៀកបំពាក់ ឬវៃផ្លាកយីហោ និងវៃផ្លាតម្លៃលក់ជាដើម ។

១០) រៀបចំ ឬរើសខោអាវតាមផ្នែកផ្សេងៗគ្នា សម្រាប់បោកសំអាត

១១) ការត្រួតពិនិត្យមើលផលិតផលនានា

១២) ការងារបញ្ចូនឯកសារផ្ទៃក្នុងអង្គភាព

១៣) ការយកសំបុត្រ ឬកញ្ចប់បញ្ញើស្រាលៗ ព្រមទាំងការចែកចាយសារព័ត៌មាន និងឯកសារផ្សេងៗ

១៤) ការរៀបចំទុកដាក់សៀវភៅនៅក្នុងបណ្ណាល័យ

១៥) លើកដាក់ឥវ៉ាន់ លី សែង យួរ កាន់របស់ស្រាលៗ NQHS

**ប្រការ ៣.-** នៅពេលជួលកុមារចាប់ពីអាយុ១២ ទៅ ១៥ឆ្នាំ និយោជកត្រូវឱ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារនោះ យល់ដឹងអំពីលក្ខខណ្ឌការងារនៃការជួល រួមមានថិរវេលាធ្វើការងាររបស់កុមារ ពេលវេលាសម្រាប់ទៅសាលារៀន ភាពងាយរងគ្រោះថ្នាក់ និងជម្ងឺដែលបណ្តាលមកពីការងារ វិធានការអនាម័យ និងសុវត្ថិភាពការងារដែលត្រូវបានអនុម័ត។ និយោជកមានភារកិច្ចជម្រុញលើកទឹកចិត្តកុមារឱ្យទៅសាលារៀន។

**ប្រការ ៤.-** ថិរវេលាធ្វើការងារប្រចាំថ្ងៃមិនត្រូវឱ្យលើសពី ៤ម៉ោង ចំពោះថ្ងៃសិក្សារៀនសូត្រ និងមិនលើសពី ៧ម៉ោង ចំពោះថ្ងៃសម្រាកពីការសិក្សា។

ថិរវេលាធ្វើការងារជាក់ស្តែងសរុបមិនត្រូវឱ្យលើសពី ១២ម៉ោង ក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឱ្យលើសពី ៣៥ម៉ោង ក្នុងមួយសប្តាហ៍សម្រាប់សប្តាហ៍ឈប់សម្រាកពីការសិក្សា។

នៅទីកន្លែងដែលកុមារធ្វើការងារសម្រាប់និយោជកលើសពីមួយនាក់ ថិរវេលាធ្វើការងាររបស់កុមារ ត្រូវគណនាបញ្ចូលគ្នា។ នៅទីកន្លែង ដែលថិរវេលាធ្វើការងារប្រចាំថ្ងៃរបស់កុមារលើសពី ៤ម៉ោង និង ៣០នាទី នោះកុមារ ធ្វើការងារត្រូវបានឈប់សម្រាកយ៉ាងហោចណាស់ ៣០នាទី។ ការឈប់សម្រាកត្រូវរៀបចំឱ្យបានឈប់សម្រាកតែមួយដង។

**ប្រការ ៥.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ ឆ្នាំ មិនត្រូវធ្វើការពីម៉ោង ២០:០០ ដល់ ម៉ោង ០៦:០០ ព្រឹកទេ។

**ប្រការ ៦.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ឆ្នាំ ត្រូវទទួលបានរយៈពេលឈប់សម្រាកយ៉ាងហោចណាស់ ១៤ម៉ោង បន្តបន្ទាប់គ្នាក្នុងថិរវេលា ២៤ម៉ោង។

**ប្រការ ៧.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ឆ្នាំ ដែលធ្វើការងារស្រាល១ត្រូវទទួលបានថ្ងៃឈប់សម្រាកពីរថ្ងៃជាប់គ្នាក្នុងសប្តាហ៍នីមួយៗ។ ប៉ុន្តែ ជាធម្មតាមួយថ្ងៃគួរជាថ្ងៃអាទិត្យ។

**ប្រការ ៨.-** ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ១០៦ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ មន្ត្រីត្រួតពិនិត្យការងារនេះ ត្រូវឃ្លាំមើលជាប្រចាំនូវបញ្ជីប្រភេទការងារស្រាលដូចមានចែងក្នុងប្រការ២នៃប្រកាសនេះ ដើម្បីកំណត់អំពីការលើកលែងចាំបាច់ដែលសមស្រប។ នៅក្នុងការប្រតិបត្តិនេះ មន្ត្រីត្រួតពិនិត្យត្រូវតែអនុវត្តតាមប្រការ៨ ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ។/.

៣

**ប្រការ ៩.-** អ្នកប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

វង សូត

**<u>ចំលងជូន :</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខអាន
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"

- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

"ដើម្បីអនុវត្ត"

- សហព័ន្ធសហជីព

"ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍

"ដើម្បីជួយផ្សព្វផ្សាយ"

- កាលប្បវត្តិ និងឯកសារ

៤

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៥៤០ **ក.ប/ប្រ.ក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១

**ប្រកាស**

**ស្តីពី**

**លក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មដំឡូងមី**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ប្រការ១.-**

ប្រកាសនេះមានគោលដៅធានា ដកហូត ការពារ និងទប់ស្កាត់ កុមារពីការងារប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរផលិតកម្មដំឡូងមី ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨, លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

ពាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

- កុមារៈ សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជកៈ សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឲ្យធ្វើការ
- ការងារកុមារក្នុងផលិតកម្មដំឡូងមីៈ សំដៅលើការចូលរួមរបស់កុមារក្នុងដំណាក់កាលរៀបចំដី ដំណាក់កាលនៃ

១

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥*

ការដាំដុះការលូតលាស់របស់ដំឡូងមី ដំណាក់កាលប្រមូលផល និងបន្ទាប់ពីការប្រមូលផល

- **ការងារប្រកបដោយគ្រោះថ្នាក់ៈ** សំដៅលើការងារទាំងឡាយណា ដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់កុមារ ដែលកើតឡើងក្នុងមុខរបរផលិតកម្មដំឡូងមី ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់ រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំដូចមានជាអាទិ៍ៈ ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី ការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ ការភ្ជួររាស់ និងការដកមើមដំឡូងចេញពីក្នុងដី។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងផលិតកម្មដំឡូងមីមានដូចតទៅ ៖

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរផលិតកម្មដំឡូងមី ប៉ុន្តែមិនឲ្យលើសពី ៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី ៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាក
- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំមិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរផលិតកម្មដំឡូងមីជាប់គ្នារហូតលើសពី ៤ម៉ោង និង៣០នាទីដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទីក្នុងមួយលើកៗ
- និយោជកត្រូវផ្តល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារក្នុងមុខរបរផលិតកម្មដំឡូងមី ដូចជា ម៉ាស់ និងស្រោមដៃ អាវភ្លៀង មួកពាក់ការពារកំដៅថ្ងៃ ដាក់ស្រោម ឬរ៉ាំបិតឲ្យជិតនៅពេលដាក់តាមខ្លួន ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ
- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មដំឡូងមី ដូចមានជាអាទិ៍ៈ ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ
- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំធ្វើការងារធ្ងន់ៗក្នុងមុខរបរផលិតកម្មដំឡូងមីដូចមានជាអាទិ៍ៈ ការភ្ជួររាស់ និងការដកមើមដំឡូងចេញពីក្នុងដី
- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំដល់ក្រោម១៨ឆ្នាំលើកដាក់ទម្ងន់លើសពី ៦គីឡូក្រាមសម្រាប់កុមារី និងលើសពី ១២គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរផលិតកម្មដំឡូងមី
- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មដំឡូងមី ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការធ្វើការដកហូតកុមារតាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តតួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

២

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ខេង សុត

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

"ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់ "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

៣

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : [illegible] ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែធ្នូ ឆ្នាំ២០១១

**ប្រកាស**
**ស្តីពី**
**ការងារកុមារក្នុងមុខរបរនេសាទទឹកសាប**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨, ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ប្រការ១.-**

ប្រកាសនេះមានគោលដៅជានា ដកហូត ការពារ និងទប់ស្កាត់ កុមារពីការងារ ប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរនេសាទទឹកសាបស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨, លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖
- កុមារ: សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជក: សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឲ្យធ្វើការ

១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

- **ការងារកុមារក្នុងមុខរបរនេសាទទឹកសាបៈ** សំដៅលើការចូលរួមរបស់កុមារក្នុងដំណាក់កាលនៃការរៀបចំឧបករណ៍នេសាទ ដំណាក់កាលនេសាទ ដំណាក់កាលប្រមូលផល និងក្រោយពេលប្រមូលផលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ

- **ការងារប្រកបដោយគ្រោះថ្នាក់ៈ** សំដៅលើការងារទាំងឡាយណាដែលបណ្ដាលឲ្យគ្រោះថ្នាក់ដល់កុមារដែលកើតឡើងក្នុងមុខរបរនេសាទទឹកសាប ព្រមទាំងបណ្ដាលឲ្យប៉ះពាល់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំ ដូចមានជាអាទិ៍ៈ នេសាទនៅតំបន់ដែលមានទឹកជ្រៅចុះជ្រមុជទឹកជ្រៅ នេសាទម្នាក់ឯងនៅតំបន់ទឹកជ្រៅ និងការអូសអួនជាដើម។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងមុខរបរនេសាទទឹកសាបមានដូចតទៅ ៖

-កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរនេសាទទឹកសាប ប៉ុន្តែមិនឲ្យលើសពី៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្ដាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្ដាហ៍សម្រាប់ថ្ងៃឈប់សម្រាក

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំមិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរនេសាទទឹកសាបជាប់គ្នារហូតលើសពី៤ ម៉ោង និង៣០នាទីដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទីក្នុងមួយលើកៗ

- និយោជកត្រូវផ្ដល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី ១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារក្នុងមុខរបរនេសាទទឹកសាបដូចជា អាវភ្លៀង ការពារក្នុងពេលភ្លៀង មួកពាក់ការពារកំដៅថ្ងៃ ដាក់ស្រោម ឬរ៉ាំប៊ិត និងឧបករណ៍នេសាទស្រួចៗ ឲ្យជិតនៅពេលដាក់តាមខ្លួន អាវសុវត្ថិភាព ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ

- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំធ្វើនេសាទនៅតំបន់ដែលមានទឹកជ្រៅនៅពេលយប់ ចន្លោះពីម៉ោង ៨ យប់រហូតដល់ម៉ោង ៦ព្រឹក និងចុះជ្រមុជទឹកជ្រៅ

- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ ធ្វើនេសាទនៅពេលយប់ ចន្លោះពីម៉ោង ៨យប់រហូតដល់ម៉ោង ៦ព្រឹកធ្វើនេសាទម្នាក់ឯងនៅតំបន់ទឹកជ្រៅ និងអូសអួន

- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំដល់ក្រោម១៨ឆ្នាំលើកដាក់ទម្ងន់លើសពី ៦គីឡូក្រាមសម្រាប់កុមារី និងលើសពី ១២គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរនេសាទទឹកសាប

- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរនេសាទទឹកសាប ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការធ្វើការដកហូតកុមារ តាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្ដារនីតិសម្បទាដើម្បីទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀតដែលទទួលបានពីសហគមន៍អ្នកផ្ដល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

២

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ចេង សុត

**<u>ចម្លងជូន ៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

" ដើម្បីអនុវត្ត"

- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

" ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់" ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

៣

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ២៤២ ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១

**ប្រកាស**

**ស្តីពី**

**ការងារកុមារក្នុងមុខរបរកសិកម្ម**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ប្រការ១.-**

ប្រកាសនេះមានគោលដៅជានា ដកហូត ការពារ និងទប់ស្កាត់កុមារពីការងារប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរកសិកម្ម ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨,លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

- កុមារៈ សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជកៈ សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឲ្យធ្វើការ
- ការងារកុមារក្នុងមុខរបរកសិកម្ម សំដៅលើការចូលរួមរបស់កុមារ ក្នុងការរៀបចំដីដើម្បីដាំដុះ ការដាំដុះ ការថែទាំ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

- ការងារកុមារក្នុងមុខរបរកសិកម្ម សំដៅលើការចូលរួមរបស់កុមារ ក្នុងការរៀបចំដីដើម្បីដាំដុះ ការដាំដុះ ការថែទាំ ការប្រមូលផល/ក្រោយការប្រមូលផល ការចិញ្ចឹមសត្វ ការដាំបន្លែ/ដំណាំរួមផ្សំ

- ការងារប្រកបដោយគ្រោះថ្នាក់ៈ សំដៅលើការងារទាំងឡាយណា ដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់កុមារដែលកើតឡើងក្នុងមុខរបរកសិកម្ម ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំ ដូចមានជាអាទិ៍ៈ ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ ការភ្ជួររាស់ ការដកសំណាប និងការច្រូតកាត់ ការលើកដាក់ទម្ងន់ធ្ងន់ជាដើម ។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងមុខរបរកសិកម្មមានដូចតទៅៈ

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម ១៥ឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរកសិកម្ម ប៉ុន្តែមិនឲ្យលើសពី ៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាក

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម ១៥ឆ្នាំមិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរកសិកម្មជាប់គ្នាហួសលើសពី ៤ម៉ោង និង៣០នាទី ដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទីក្នុងមួយលើកៗ

- និយោជកត្រូវផ្តល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារក្នុងមុខរបរកសិកម្មដូចជា អាវភ្លៀង ស្រោមដៃ ស្បែកជើងកវែង មួកពាក់ការពារកំដៅថ្ងៃ ដាក់ស្រោម ឬឧបករណ៍មុតស្រួច ឲ្យជិតនៅពេលដាក់តាមខ្លួន ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ

- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរកសិកម្ម ដូចមានជាអាទិ៍ៈ ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ

- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម ១៥ឆ្នាំធ្វើការងារធ្ងន់ៗ ក្នុងមុខរបរកសិកម្មដូចមានជាអាទិ៍ៈ ការភ្ជួររាស់ ការដកសំណាប និងការច្រូតកាត់

- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ លើកដាក់ទម្ងន់លើសពី ៦ គីឡូក្រាម សម្រាប់កុមារី និងលើសពី ១២ គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរកសិកម្ម

- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរកសិកម្ម ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការ ធ្វើការដកហូតកុមារទៅតាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្ដីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**វង សុត**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

"ដើម្បីជូនជ្រាប"

- គ្រប់បណ្ដាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់ "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

៣

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ១៤៣ ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១

## ប្រកាស
## ស្តីពី
## លក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មថ្នាំជក់

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/003 ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅធានា ដកហូត ការពារ និងទប់ស្កាត់កុមារពីការងារប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរផលិតកម្មថ្នាំជក់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨, លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

- កុមារៈ សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជកៈ សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឱ្យធ្វើការ

១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ (០២៣) ៨៨ ៤៣ ៧៥ និងទូរសារៈ (០២៣) ៨៨ ២៧ ៦៥

- ការងារកុមារក្នុងផលិតកម្មថ្នាំជក់: សំដៅលើការចូលរួមរបស់កុមារក្នុងដំណាក់កាលរៀបចំថ្នាល ដើម្បីបណ្តុះពូជ ដំណាក់កាលនៃការដាំដុះ ការលូតលាស់របស់ថ្នាំជក់ ដំណាក់កាលប្រមូលផល និងបន្ទាប់ពីការប្រមូលផល

- ការងារប្រកបដោយគ្រោះថ្នាក់: សំដៅលើការងារទាំងឡាយណា ដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់កុមារដែលកើតឡើងក្នុងមុខរបរផលិតកម្មថ្នាំជក់ ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំ ដូចមានជាអាទិ៍: ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ ការក្ចូររាស់ ការដោតស្លឹកថ្នាំជក់ជាចង្កាក់ និងដាក់ថ្នាំក្នុងឡ។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មថ្នាំជក់មានដូចជា ៖

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ អាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរផលិតកម្មថ្នាំជក់ ប៉ុន្តែមិនឲ្យលើសពី ៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី ៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាក

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ មិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរផលិតកម្មថ្នាំជក់ជាប់គ្នារហូតលើសពី ៤ម៉ោង និង៣០នាទី ដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទី ក្នុងមួយលើកៗ

- និយោជកត្រូវផ្តល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារ ក្នុងមុខរបរផលិតកម្មថ្នាំជក់ ដូចជាម៉ាស់និងស្រោមដៃ អាវភ្លៀង មួកពាក់ការពារកំដៅថ្ងៃ ជាក់ស្រោម ឬក៏បិតឲ្យជិតនៅពេលដាក់តាមខ្លួន ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ

- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មថ្នាំជក់ ដូចមានជាអាទិ៍: ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ

- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំធ្វើការងារធ្ងន់ៗក្នុងមុខរបរផលិតកម្មថ្នាំជក់ ដូចមានជាអាទិ៍: ការក្ចូររាស់ ការដោតស្លឹកថ្នាំជក់ជាចង្កាក់ និងដាក់ថ្នាំក្នុងឡ

- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំលើកដាក់ទម្ងន់លើសពី ៦ គីឡូក្រាម សម្រាប់កុមារី និងលើសពី ១២ គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរផលិតកម្មថ្នាំជក់

- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មថ្នាំជក់ ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការធ្វើការដកហូតកុមារ តាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

២

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

វ៉ង សុត

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

" ដើម្បីអនុវត្ត"

- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

" ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់" ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :............៤៣៩............ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេង នៅតាមសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨ នៃអង្គការអន្តរជាតិខាងការងារ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស រោងចក្រ គ្រឹះស្ថាន។

១/៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ២.-**

កម្មករនិយោជិតវ័យក្មេងសំដៅទៅលើកុមារ ដែលមានអាយុអប្បបរមាអាចចូលបម្រើការងារបាន ចាប់ពីអាយុ១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា១៧៧ នៃច្បាប់ស្តីពីការងារ។

**ប្រការ ៣.-**

នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេង មានគោលដៅកំណត់លក្ខខណ្ឌការងារសមរម្យអាចអនុញ្ញាតឱ្យកម្មករនិយោជិតវ័យក្មេងធ្វើការងារបាន លុះត្រាតែការងារទាំងនោះមិនធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងការរីកលូតលាស់នៃរាងកាយ ផ្លូវចិត្ត និងមិនប៉ះពាល់ដល់ការចូលរៀននៅក្នុងសាលារៀន ឬការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលនានារបស់ពួកគេឡើយ។

**ប្រការ ៤.-**

ហាមនិយោជកនៃសហគ្រាស រោងចក្រ គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ប្រើប្រាស់កុមារដែលមានអាយុពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ នៅក្នុងលក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ កម្មករនិយោជិតវ័យក្មេងអាចចូលបម្រើការងារបាន លុះត្រាតែបំពេញតាមនីតិវិធីដូចមានចែងក្នុងប្រការ ៥ ៦ និងប្រការ៧ នៃប្រកាសនេះ។

**ប្រការ ៥.-**

និយោជកមុនពេលជ្រើសរើសកម្មករនិយោជិតវ័យក្មេង ឱ្យចូលបម្រើការងារនៅក្នុងសហគ្រាស រោងចក្រ គ្រឹះស្ថាន ត្រូវអនុវត្តដូចតទៅ៖

- និយោជកត្រូវត្រួតពិនិត្យឯកសារឱ្យបានត្រឹមត្រូវយ៉ាងហោចណាស់ចំនួន៣ ក្នុងចំណោមឯកសារដូចខាងក្រោម៖
    - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ
    - សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្រកំណើត
    - លិខិតបញ្ជាក់សញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សា
- និយោជកត្រូវសម្ភាសន៍ជាមួយកម្មករនិយោជិតវ័យក្មេង ដោយមានការដឹងឮ និងធានាអះអាងពីមាតា បិតា ឬអាណាព្យាបាល ដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃឯកសារ និងលក្ខណៈរូបសាស្ត្ររបស់កម្មករ និយោជិតវ័យក្មេង
- និយោជកត្រូវមានកិច្ចសន្យាការងារដែលមានការយល់ព្រមពីមាតា បិតា ឬអាណាព្យាបាលរបស់កម្មករនិយោជិតវ័យក្មេង ស្របតាមមាត្រា១៨១នៃច្បាប់ស្តីពីការងារ
- ក្នុងករណីសង្ស័យអំពីកម្មករនិយោជិតមានអាយុក្រោមច្បាប់កំណត់ និយោជកត្រូវបញ្ជូនឯកសារមកនាយកដ្ឋានការងារកុមារ និងនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ជាក់អត្តសញ្ញាណ កាយសម្បទា និងលក្ខខណ្ឌសុខភាពដែលអាចអនុញ្ញាតឱ្យធ្វើការបាន
- និយោជកត្រូវបញ្ជូនសំណុំឯកសារ ក្នុងនោះត្រូវមានបញ្ជីរាយនាមកម្មករនិយោជិតវ័យក្មេង និងពាក្យស្នើសុំទិដ្ឋាការ មកនាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ការអនុញ្ញាតប្រើប្រាស់កម្មករនិយោជិតវ័យក្មេង
- និយោជកត្រូវមានសៀវភៅបញ្ជីសម្រាប់ចុះនាមកម្មករនិយោជិតវ័យក្មេង ដែលមានអាយុចាប់ពី១៥ឆ្នាំដល់ក្រោម១៨ឆ្នាំ ប្រចាំនៅសហគ្រាស រោងចក្រ គ្រឹះស្ថាន។

**ប្រការ ៦.-**

ក្នុងអំឡុងពេលដែលកម្មករនិយោជិតវ័យក្មេងចូលធ្វើការ និយោជកនៃសហគ្រាស រោងចក្រ គ្រឹះស្ថាន ត្រូវគោរពនីតិវិធីដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ ច្បាប់ស្តីពីការងារ និងប្រកាសពាក់ព័ន្ធពលកម្មកុមារ ដូចខាងក្រោម៖

- មិនត្រូវឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ត្រូវធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ
- មិនអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង ធ្វើការនៅថ្ងៃអាទិត្យ ថ្ងៃឈប់សម្រាក និងធ្វើការពេលយប់ចន្លោះពីម៉ោង២២:០០ដល់ម៉ោង៥:០០ភ្លឺ
- និយោជកត្រូវគោរពទៅតាមបទប្បញ្ញត្តិ និងបទដ្ឋាននានាដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ ជាធរមាន។

**ប្រការ ៧.-**

ក្រោយពេលកម្មករនិយោជិតវ័យក្មេងទទួលបានការងារ និយោជក និយោជិត ប្រតិភូបុគ្គលិក សហជីព និងភាគីពាក់ព័ន្ធត្រូវអនុវត្ត ដូចតទៅ៖

- និយោជកត្រូវតម្កល់ទុកឯកសារ បញ្ជីស្នាម និងលិខិតបញ្ជាក់នានា ដើម្បីសម្រួលដល់អាជ្ញាធរ ឬសមត្ថកិច្ចធ្វើការត្រួតពិនិត្យតាមដានកម្មករនិយោជិតវ័យក្មេងនេះ
- យ៉ាងហោចណាស់មួយឆ្នាំម្តង ចាប់ផ្តើមពីចូលបម្រើការងារ រហូតដល់កម្មករនិយោជិតវ័យក្មេងអាយុ១៨ឆ្នាំ ត្រូវពិនិត្យសុខភាពឱ្យបានត្រឹមត្រូវ និងបញ្ជាក់ដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ករណីសង្ស័យកុមារមានសភាពស្លេកស្លាំង សុខភាពទ្រុឌទ្រោម ឬអាចប្រឈមនឹងគ្រោះថ្នាក់ការងារដោយប្រការណាមួយ និយោជកត្រូវដកហូតកម្មករនិយោជិតវ័យក្មេងជាបន្ទាន់ និងត្រូវផ្តល់ការស្តារនីតិសម្បទា ដើម្បីកុមារត្រឡប់មកទទួលការងារសមរម្យ។
- និយោជិត ប្រតិភូបុគ្គលិក សហជីព និងភាគីពាក់ព័ន្ធត្រូវចូលរួមរាយការណ៍មកនាយកដ្ឋានការងារកុមារក្នុងករណីសង្ស័យខាងលើ ដើម្បីការពារឧត្តមប្រយោជន៍កុមារ។

**ប្រការ ៨.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយណានៃប្រកាសនេះ ត្រូវពិន័យឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦នៃច្បាប់ស្តីពីការងារ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព
- ឯកសារ កាលប្បវត្តិ

៣/៣

# សេចក្តីសម្រេច

ពិភាករណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...១៥.....សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨នៃអង្គការអន្តរជាតិខាងការងារស្ដីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្ដីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

១/ ៣

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ពិភាក្សារួច

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- លោកជំទាវ **ស៊ើង សរសុចិត្តា** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- លោកជំទាវ **ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥- លោកជំទាវ **ខៀវ មូរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦- ឯកឧត្តម **អ៊ឹម កុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧- ឯកឧត្តម **ចាន់ រ៉ាស៊ី** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- ឯកឧត្តម **ថាច់ ភេត** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៩- លោកជំទាវ **ឃុន ថារី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០- លោកជំទាវ **ឌិត លីនដា** | អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១១- លោកជំទាវ **ម៉ុម ថានី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- ឯកឧត្តម **ហេ ភាន់** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- ឯកឧត្តម **ស៊ា កុសល** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- លោកជំទាវ **កែវ ចរិយា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៥- ឯកឧត្តម **សួរ ចាន់ធី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៦- លោកជំទាវ **សួស រដ្ឋាវី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧- ឯកឧត្តម **ថោង ពោដ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨- ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩- ឯកឧត្តម **លេង ផាលី** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ២០- លោកជំទាវ **ម៉ែន វិភស៊ី** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២១- ឯកឧត្តម **ហ៊ាង ស៊ីណោ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២- លោកជំទាវ ឧត្តមសេនីយ៍ឯក **យក់ សុខា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន | នគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |

២/៣

**និរាករណ៍**

២៣- លោកជំទាវ ឧត្តមសេនីយ៍ឯក **ឌុច ដាណា** អគ្គនាយករង នៃអគ្គនាយកដ្ឋាន អគ្គសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ — សមាជិក

២៤- ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន — សមាជិក

២៥- ឯកឧត្តម **ហោច សួរ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក

២៦- ឯកឧត្តម **សេង សក្តា** អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក

២៧- ឯកឧត្តម **ឡៅ ហ៊ីម** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក

២៨- លោកជំទាវ **ញ៉ែប សុនាព** អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ — សមាជិក

២៩- អគ្គលេខាធិការ **គ.ជ.ព.** — សមាជិកអចិន្ត្រៃយ៍។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ...៧៧ ស.ស.រ**

## សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨ នៃអង្គការអន្តរជាតិខាងការងារស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

១/៣

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- លោកជំទាវ | **ស៊ើង សរសុមិត្តា** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- លោកជំទាវ | **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- លោកជំទាវ | **ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥- លោកជំទាវ | **ខៀវ មុរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦- ឯកឧត្តម | **អ៊ឹម កុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧- ឯកឧត្តម | **ចាន់ រ៉ាស៊ី** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- ឯកឧត្តម | **ថាច់ ខេត** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៩- លោកជំទាវ | **ឃុន ម៉ារី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិកា |
| ១០- ឯកឧត្តម | **សុះ ណារុន** | អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១១- លោកជំទាវ | **ចាន់ ផលធឿន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកា |
| ១២- ឯកឧត្តម | **សេត មូហាំម៉ាត់ស៊ីស** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- លោកជំទាវ | **អែម ចរិយា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកា |
| ១៤- ឯកឧត្តម | **សូរ ចាន់ធី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៥- លោកជំទាវ | **សួស រដ្ឋាធី** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ១៦- ឯកឧត្តម | **ចោង ពោជ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧- ឯកឧត្តម | **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៨- ឯកឧត្តម | **អង សុសាធី** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៩- លោកជំទាវ | **អ៊ុំ សាម៉ុល** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិកា |
| ២០- ឯកឧត្តម | **ហ៊ាង ស៊ីណោ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២១- ឯកឧត្តម | **ទូ សំណាង** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២២- លោកជំទាវ នាយឧត្តមសេនីយ៍ | **យស់ សុខា** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិកា |
| ២៣- លោកជំទាវ ឧត្តមសេនីយ៍ឯក | **ឌុច ដាណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិកា |
| ២៤- ឯកឧត្តម នាយឧត្តមសេនីយ៍ | **មាស វីរិទ្ធ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ២៥- ឯកឧត្តម | **សេង សក្ដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

២/៣

២៦- ឯកឧត្តម **ហាំង គុណា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៧- ឯកឧត្តម **ហ៊ីង ស៊ីដេត** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៨- លោកជំទាវ **ញ៉ៀម សុភាព** អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិកា

២៩- ឯកឧត្តម **ម៉េង ហៀង** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ សមាជិកអចិន្ត្រៃយ៍។

**ប្រការ២.-**

សេចក្តីសម្រេចលេខ១៥ សសរ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣/៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ០៥៨/២២ ក.ប/ស.ស.រ.ខ.ល

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់សិក្សាស្រាវជ្រាវលទ្ធភាពផ្តល់ការអប់រំសិក្សាដល់កុមារ ដែលស្ថិតក្រោមអាណាព្យាបាលរបស់ កម្មករនិយោជិតចំណាកស្រុក និងពលករទៅធ្វើការនៅក្រៅប្រទេស

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារសម្រាប់សិក្សាស្រាវជ្រាវលទ្ធភាពផ្តល់ការអប់រំសិក្សាដល់កុមារដែលស្ថិតក្រោមអាណាព្យាបាលរបស់កម្មករនិយោជិតចំណាកស្រុក និងពលករទៅធ្វើការនៅក្រៅប្រទេស ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ទុយ ស៊ីផាន់** | រដ្ឋលេខាធិការ | ប្រធាន |
| ២-លោកជំទាវ **សួស រដ្ឋាវី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម **ទេព ណាវី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម **ប៉ាន់ ណូរ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥-ឯកឧត្តម **អ៊ិត ដារ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦-ឯកឧត្តម **ថង សាម៉ុន** | ទីប្រឹក្សាក្រសួង និងជាអគ្គនាយករង TVET | សមាជិក |
| ៧-ឯកឧត្តម **ឆាង ស៊ាងខេង** | ទីប្រឹក្សាក្រសួង និងជាអគ្គនាយករងការងារ | សមាជិក |

| | | | |
|---|---|---|---|
| ៨-ឯកឧត្តម | **តាន់ សម្បត្តិ** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋានគ្រប់គ្រងស្ថានសិក្សា | សមាជិក |
| ៩-លោក | **តាំង ផេងរិទ្ធី** | អគ្គនាយករងការងារ | សមាជិក |
| ១០- លោក | **ភីម ចំរើន** | អគ្គនាយករងការងារ | សមាជិក |
| ១១- លោក | **ខេម ម៉ីនឈាន** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១២- លោក | **ទៀង ធិត្យាភោគមល** | ប្រធាននាយកដ្ឋានមុខរបរនិងហត្ថពលកម្ម | សមាជិក |
| ១៣- លោកស្រី | **ឃុន លក្ខិណា** | ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល | សមាជិកា |
| ១៤- លោកស្រី | **ម៉ុក ករុណា** | ប្រធាននាយកដ្ឋានស្ដីទីនាយកដ្ឋានការងារកុមារ | សមាជិកា |
| ១៥- លោក | **ឃឹម សុសំរេច** | ប្រធានការិយាល័យរកការឱ្យធ្វើនៅបរទេសទី២ | សមាជិក |
| ១៦- លោក | **ម៉ី ចន្ទបណ្ឌិត** | ប្រធានការិយាល័យរកការឱ្យធ្វើនៅបរទេសទី១ | សមាជិក |
| ១៧- លោកស្រី | **ហួន សុគន្ធា** | ប្រធានការិយាល័យរកការឱ្យធ្វើនៅបរទេសទី៣ | សមាជិកា |

**ប្រការ២.-**

ក្រុមការងារសម្រាប់សិក្សាស្រាវជ្រាវលទ្ធភាពផ្ដល់ការអប់រំសិក្សាដល់កុមារដែលស្ថិតក្រោមអាណាព្យាបាលរបស់កម្មករនិយោជិតចំណាកស្រុក និងពលករទៅធ្វើការនៅក្រៅប្រទេស មានភារកិច្ចដូចតទៅ៖

- សិក្សា ប្រមូលចងក្រងទិន្នន័យទៅលើមុខសញ្ញាកម្មករនិយោជិតដែលចំណាកស្រុកមកធ្វើការនៅតាមទីប្រជុំជន ជាពិសេសនៅតាមការដ្ឋានសំណង់ធំៗដែលមកធ្វើការដោយមានកុមារយកមកស្នាក់នៅជាមួយ ដើម្បីទទួលបានឱកាសសិក្សារៀនសូត្រ
- សិក្សាក្នុងការផ្ដល់ជម្រើសជូនដល់កុមារដែលស្ថិតក្រោមអាណាព្យាបាលរបស់កម្មករនិយោជិត និងពលករ ទទួលបានឱកាសចូលរៀន តាមសាលាក្បែរកន្លែងធ្វើការរបស់កម្មករនិយោជិត ឬរកគ្រូចល័តមកបង្រៀនដល់កន្លែងស្នាក់នៅក្បែរការដ្ឋាន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងជាមួយអាជ្ញាធរដែនដី
- រៀបចំរបាយការណ៍ និងស្វែងរកដំណោះស្រាយផ្សេងៗឆ្លើយតបទៅនឹងបញ្ហាដែលកើតមានឡើង
- រៀបចំផែនការសកម្មភាពការងារ គម្រោងថវិកា និងរបាយការណ៍សកម្មភាពការងារដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈពិនិត្យសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាមីខ្លួន ដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រី**

**កន្លែងទទួល:**
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី-ខេត្ត
- ដូចប្រការ១
- ឯកសារ កាលប្បវត្តិ

២/២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

តែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហេង សួរ** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- លោកជំទាវ | **សួស រដ្ឋាវី** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |

១/៣

| | | | |
|---|---|---|---|
| ៣- លោកជំទាវ | **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- លោកជំទាវ | **ហ៊ី សាមិត្ត** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥- លោកជំទាវ | **ខៀវ បូរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦- ឯកឧត្តម | **អ៊ឹម កុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧- លោកជំទាវ | **ឃុន ថារី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកា |
| ៨- ឯកឧត្តម | **ហោ សារុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩- ឯកឧត្តម | **អ៊ុក ឌី** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- លោកជំទាវ | **នង ធួក** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិកា |
| ១១- ឯកឧត្តម | **សុះ ណូរុន** | អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១២- ឯកឧត្តម | **សុខ វិសាល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- ឯកឧត្តម | **បាន កុសល** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- ឯកឧត្តម | **កែវ វិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- លោកជំទាវ | **លីម ឈុននី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកា |
| ១៦- លោកជំទាវ | **សុខ ឆវ័ន្ត** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិកា |
| ១៧- ឯកឧត្តម | **ម៉េង ហៀង** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨- លោកជំទាវ | **ឡាយ ទីរៈបុត្រ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិកា |
| ១៩- ឯកឧត្តម | **សេង សឿន** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ២០- ឯកឧត្តមឧិសថការី | **បាន បុត្តា** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២១- ឯកឧត្តម | **កុលផេង វឌ្ឍនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជីវ ផល្លី** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាន នគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៣- លោកជំទាវ ឧត្តមសេនីយ៍ឯក | **លីម រស្មី** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិកា |
| ២៤- ឯកឧត្តម នាយឧត្តមសេនីយ៍ | **មាស វិរិទ្ធ** | អគ្គលេខាធិការនៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ២៥- ឯកឧត្តម | **ហាំង តុលា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៦- ឯកឧត្តម | **សេង សក្កា** | អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

២/៣

២៧- ឯកឧត្តម **ហ៊ីង ស៊ីដេត** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៨- ឯកឧត្តម **គីម សុវណ្ណឌី** អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក

២៩- លោកជំទាវ **ប៉ុក ករុណា** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ សមាជិកាអចិន្ត្រៃយ៍។

**ប្រការ២.-**

សេចក្តីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣/៣

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

**Publication supported by**

TAFTAC
Textile, Apparel, Footwear & Travel Goods Association in Cambodia

CAMFEBA

C.J.K.A. Cambodia-Japan Kibou Association

BSEA Cambodia's Bag, Shoe and Electronic Association

CTLA Cambodia Travel Goods and Leather Association

CFA Cambodia Footwear Association (CFA)